ការសែតចេញផ្សាយ
ប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ
# the messenger

ខែមេសា ឆ្នាំ២០២០ | លេខទី ១២៦

តម្លៃលក់១ពាន់រៀល

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ www.khmer.rvasia.org/

April, 2020 | #126


## «ពិធីប្រសិទ្ធពរលើប្រេងគ្រីស្មា»

### ធ្វើដោយសាមញ្ញ និងស្ងៀមស្ងាត់ ក្នុងពេលកូវីដ១៩


ទំព័រ-១៨-១៩
ទស្សនាវីដេអូទីនេះ







## ពលរដ្ឋត្រូវប្រុងប្រយ័ត្ន និងការពារ សុខភាពពី បញ្ហាអាកាសធាតុ


ទំព័រ៖១០-១១







*ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២០*

**អាទិត្យទី៤ នៃរដូវអប់រំពិសេស**

*«ក្រុងយេរូសាឡឹមអើយ ចូរសប្បាយរីករាយ»* អស ៦៦,១០

លោកឪពុកជាទីស្រឡាញ់

បងប្អូនជាទីស្រឡាញ់ បព្វជិត បព្វជិតាសាសនទូតនានា និងបងប្អូនជំហានទី២

បងប្អូនដែលកំពុងស្វែងរកព្រះយេស៊ូជាទីស្រឡាញ់

យើង! ជាអ្នកគង្វាលនៃព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា ពីព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម និងព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ មានបំណងប្រកាសប្រាប់បងប្អូនក្នុងថ្ងៃនេះ អំពីភាពស្និទ្ធស្នាល និងការអធិដ្ឋានដ៏ក្លៀវក្លារបស់យើងសម្រាប់បងប្អូនគ្រប់គ្នា និងសម្រាប់ពិភពលោកដែលកំពុងតស៊ូជាមួយមេរោគកូវីដ១៩ (Covid-១៩) ដ៏កំណាច។

នៅក្នុងប្រទេសកម្ពុជា ដំបូងឡើយ មានករណីជំងឺឆ្លងនេះ តែមួយករណីទេ ប៉ុន្តែគួរបញ្ជាក់ផងដែរថា រហូតមកដល់ព្រឹកថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០ ក្រសួងសុខាភិបាលបានប្រកាសថា អ្នកជំងឺកូវីដ១៩ ជាសះស្បើយមានចំនួនរហូតដល់៥នាក់ថ្មីទៀត ដែលធ្វើឱ្យចំនួនអ្នកជាសះស្បើយកើនឡើងរហូតដល់ ៥៨នាក់ ប៉ុន្តែនៅថ្ងៃនេះដែរ ក្រសួងក៏បានរកឃើញករណីឆ្លងថ្មីម្នាក់ទៀតដែរ។ សេចក្តីប្រកាសបន្តថា អ្នកកំពុងសម្រាកព្យាបាលជំងឺកូវីដធ្លាក់ចុះមកត្រឹមចំនួន៥៧នាក់ នៃអ្នកឆ្លងសរុប១១៥នាក់។។ យើងអាចចោទជាសំណួរថា តើនឹងមានអ្វីកើតឡើងទៀតនៅក្នុងរយៈពេលដប់ថ្ងៃខាងមុខនេះ នៅពេលដែលយើងឃើញនៅក្នុងប្រទេសជាច្រើនមេរោគឆ្លងនេះកំពុងផ្ទុះឡើងខ្លាំងនោះ?

ក្នុងនាមជាគង្វាលនៃព្រះសហគមន៍កាតូលិកនៅកម្ពុជា យើងបានផ្តល់អនុសាសន៍ និងការណែនាំរួចហើយ ដោយអនុវត្តសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ ស្តីពីការបិទជំនួបបែបសាសនាគ្រប់ប្រភេទទាំងអស់នៅទូទាំងប្រទេស។

យើងក៏បានដាក់ចេញនូវមធ្យោបាយជាច្រើន ដែលនាំឱ្យការអធិដ្ឋាន សាមគ្គីភាព និងក្តីសង្ឃឹមរបស់យើងនឹងត្រូវបានពង្រឹង និងលើកទឹកចិត្ត ទោះបីយើងមិនអាចជួបជុំ និងអធិដ្ឋានរួមគ្នាក៏ដោយ។

ចំពោះការជួបជុំនៅក្នុងសហគមន៍ទាំងអស់មាន៖ អភិបូជារួម ការអធិដ្ឋានរួម កិច្ចប្រជុំនានា សិក្ខាសាលាទាំងឡាយត្រូវផ្អាក រួមទាំងពិធីបុណ្យប្រសិទ្ធពរលើប្រេងគ្រីស្មា។ ផ្អាកលោកបូជាចារ្យទៅថ្វាយអភិបូជាតាមក្រុមគ្រួសារបព្វជិតបព្វជិតា។ បិទសាលាទាំងអស់ តាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០។

តើវិន័យមួយណាសំខាន់ជាងគេ?៖ «មានតែព្រះអម្ចាស់ជាព្រះរបស់យើងមួយព្រះអង្គគត់ ដែលពិតជាព្រះអម្ចាស់។ ត្រូវស្រឡាញ់ព្រះអម្ចាស់ ជាព្រះរបស់អ្នកឱ្យអស់ពីចិត្តគំនិត អស់ពីស្មារតី អស់ពីប្រាជ្ញា និងអស់កម្លាំងកាយ។ ហើយត្រូវស្រឡាញ់បងប្អូនឯទៀតៗដូចស្រឡាញ់ខ្លួនឯង»។ នេះជាបន្ទូលព្រះយេស៊ូរំឭកយើង (មក ១២,២៨-៣៤)

សូមឱ្យសេចក្តីស្រឡាញ់នេះសម្តែងចេញច្បាស់លាស់នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើង។

ខណៈដែលទន្ទឹងរង់ចាំសេចក្តីណែនាំថ្មីពី គណៈកម្មការជាតិប្រយុទ្ធនឹងកូវីដ១៩ (COVID-១៩) យើងសូមអញ្ជើញបងប្អូនបង្ហាញសេចក្តីស្រឡាញ់ ចំពោះខ្លួនឯង និងចំពោះបងប្អូនឯទៀតដូចជា៖

អនុវត្តឱ្យខ្ជាប់ខ្ជួននូវវិធានអនាម័យ ដោយលាងដៃឱ្យបានញឹកញាប់ជារៀងរាល់ថ្ងៃ រក្សាគម្លាតពីអ្នកដទៃ ធ្វើបដិសណ្ឋារកិច្ចគ្នាតាមរបៀបប្រពៃណី...និងដោយស្នាមញញឹមទៅវិញទៅមក។

ប្រសិនបើក្តៅខ្លួន ឬក្អក សូមសម្រាកនៅផ្ទះហើយពាក់ម៉ាស់ការពារ។ ប្រសិនបើមានមានអាការៈពិបាកដកដង្ហើម សូមហៅទូរសព្ទទៅលេខ១១៥ សូមចៀសវាងទៅកន្លែងសាធារណៈជួបជុំមនុស្សច្រើន។

ចៀសវាងការធ្វើដំណើរពីទីក្រុងទៅខេត្ត ឬពីខេត្តមកទីក្រុង។ សម្រាប់អ្នកធ្វើការ សូមយកចិត្តទុកដាក់ពីរបៀបទំនាក់ទំនងប្រចាំថ្ងៃជាមួយក្រុមការងារ ឬអតិថិជន...រក្សាគម្លាតពីគ្នានិងគ្នាយ៉ាងតិច១ម៉ែត្រ។

បងប្អូនជាទីស្រឡាញ់! ក្នុងឱកាសរដូវអប់រំពិសេសនេះ បានអញ្ជើញយើងឱ្យប្រតិបត្តិ៖

អធិដ្ឋាន ឱ្យបានច្រើន តាមគ្រប់មធ្យោបាយដែលយើងនឹងផ្តល់ជូនតាមប្រព័ន្ធផ្សព្វផ្សាយសង្គម (Social Media) ហើយជាពិសេស សូមរក្សាការសន្ទនាផ្ទាល់ខ្លួនយ៉ាងជិតស្និទ្ធជាមួយព្រះអម្ចាស់ជានិច្ច។ តមអាហារ តាមរបៀបថ្មី ដោយអនុវត្តតាមវិធានការណ៍ទាំង៧ខាងលើក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ ស្រឡាញ់ ឱ្យបានច្រើន ដោយភ្ជាប់ខ្លួនយើងនឹងទុក្ខវេទនារបស់ពិភពលោក ដោយនៅក្បែរអ្នកដែលទ្រហោយំ និងមានជំងឺនៅជុំវិញយើង។

*សូមព្រះជាម្ចាស់ប្រទានពរ និងថែរក្សាបងប្អូនក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ! សូមឱ្យយើងមានជំនឿរឹងមាំ ពោរពេញដោយក្តីមេត្តាករុណា និងមានសេចក្តីសង្ឃឹមជានិច្ច!*

*ពីលោកអភិបាលទាំងបី*
*នៃព្រះសហគមន៍កាតូលិកនៅកម្ពុជា*

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

**ចាងហ្វាង : លោក លី សុវណ្ណា**
សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh



# កន្លែងពិនិត្យ ថែទាំ និង ព្យាបាលអ្នកជំងឺកូវីដ១៩



*បុគ្គលិកមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត កំពុងបំពេញការងារសម្អាតបរិវេណអាគារព្យាបាលជំងឺ។* ***រូបភាព៖ មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត***

*ដោយ ៖ ផល សុផានិត*

ក្រសួងសុខាភិបាលបានសម្រេចបន្ថែមអគារនៃអតីតសណ្ឋាគារ Great DUKE សម្រាប់ថែទាំព្យាបាលអ្នកជំងឺកូវីដ១៩ និងទីតាំងមួយទៀតដែលមានចំណុះ១០០គ្រែស្ថិតនៅអតីតមណ្ឌលសុខភាពចាក់អង្រែ ក្នុងសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

យោងតាមសេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាលនៅយប់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០នេះ បានឱ្យដឹងថា ការសម្រេចបន្ថែមអគារថែទាំព្យាបាលជំងឺកូវីដនេះ បន្ទាប់ពីក្រសួងបានពិនិត្យឃើញថា មានការកើនឡើងនៃអ្នកស្នើសុំពិនិត្យធ្វើតេស្តរកជំងឺកូវីដ១៩នេះ។



*សម្តេចតេជោ ហ៊ុន សែន ក្នុងពិធីជួបសំណេះសំណាលពេទ្យស្ម័គ្រចិត្ត មុនចុះបំពេញការងារមើលថែរក្សាអ្នកជំងឺកូវីដ ១៩។* ***រូបភាព៖ ហ្វេសប៊ុកនាយករដ្ឋមន្ត្រី***

ក្រៅពីទីតាំងទើបបន្ថែមថ្មីនេះ ក្រសួងសុខាភិបាល បានរៀបចំកន្លែងថែទាំ និងព្យាបាលអ្នកជំងឺកូវីដ១៩ នៅទីតាំងជាច្រើនមានដូចជានៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យកុមារជាតិ មន្ទីរពេទ្យគន្ធបុប្ផាភ្នំពេញ មន្ទីរពេទ្យជ័យវរ្ម័នទី៧សៀមរាប និងនៅមន្ទីរពេទ្យខេត្តទាំង២៤។ ក្រសួងសុខាភិបាល ក៏បានអំពាវនាវដល់ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ចូលរួមក្នុងប្រតិបត្តិការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ផងដែរ។ បើទោះបីជាយ៉ាងណា ក្រសួងសុខាភិបាល បានអះអាងថា មកដល់ពេលនេះ កម្ពុជាមិនទាន់មានការរាតត្បាតក្នុងសហគមន៍នៅឡើយនោះទេ។

យោងទៅតាមរបាយការណ៍របស់អង្គការសុខភាពពិភពលោក មេរោគនេះបានឆ្លងរីករាលដាលដល់មនុស្ស សរុបចំនួន ១.២១៤.៩៧៣ នាក់ ហើយវាបានសម្លាប់មនុស្សសរុបចំនួនរហូតដល់ ៦៧.៨៤១ នាក់ ដោយការចម្លងនៅកាត់ទ្វីបអឺរ៉ុបមានចំនួនសរុបប្រមាណជា ៦៥៥.៣៣៩ នាក់ នៅអាមេរិក មានចំនួន ៣៥២.៦០០ នាក់នៅតំបន់ប៉ាស៊ីហ្វិកខាងលិចមាន ១១២.៥៧៨ នាក់ នៅតំបន់មេឌីទែរ៉ាណេ ខាងកើតមានចំនួន ៧៧.៣៥៩ នាក់ នៅតំបន់អាស៊ីអគ្នេយ៍យើងនេះ គឺមាន ៩.១៣២ នាក់ និងនៅអាហ្វ្រិកចំនួន ៦.៩៨៦ នាក់៕




*មណ្ឌលសុខភាពចាក់អង្រែដែលត្រូវបានប្រើប្រាស់សម្រាប់ព្យាបាលអ្នកជំងឺកូវីដ ១៩។* ***រូបភាព៖ សហការី***

## សៀមរាប-សង្ក្រាន្ត នឹងគ្មានរូបរាងទេនៅឆ្នាំនេះ!

*ដោយ ៖ អមរិន្ទ ដានុត*



រាជរដ្ឋាភិបាលបានសម្រេចលុបចោលជាថ្មីនូវការរៀបចំសៀមរាប-សង្ក្រាន្តនៅតំបន់រមណីយដ្ឋានអង្គរ បន្ទាប់ពីក្រសួងបានរកឃើញបុរសជនជាតិខ្មែរលើកទី១ វ័យ៣៨ឆ្នាំមួយរូបមានផ្ទុកជំងឺរលាក់ផ្លូវដង្ហើមកូរ៉ូណា ឬកូវីដ-១៩ នៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប។

កាលពីដើមខែមីនា រដ្ឋបាលខេត្តសៀមរាប និងអាជ្ញាធរជាតិអប្សរាបានសហការគ្នាជាមួយសហភាពសហព័ន្ធយុវជនកម្ពុជាប្រចាំខេត្ត និងស្ថាប័នពាក់ព័ន្ធផ្សេងៗ ក្នុងការរៀបចំសៀមរាប-សង្ក្រាន្តនេះ នៅបរិវេណប្រាសាទអង្គរវត្ត ដែលនឹងប្រព្រឹត្តឡើងរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៦ ខែមេសា ប៉ុន្តែគម្រោងនេះនឹងមិនអាចកើតមានឡើងឡើយ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែនបានផ្ញើសារជាសម្លេងឱ្យអាជ្ញាធរពាក់ព័ន្ធលុបចោលកម្មវិធីសៀមរាប-សង្ក្រាន្តឆ្នាំ២០២០នេះ ដើម្បីការពារសុខភាពប្រជាពលរដ្ឋពីការឆ្លងជំងឺសួតថ្មីនេះ។

លោកបានមានប្រសាសន៍ថា៖ «វាហាក់ដូចជាផ្ទុយចរន្ត យើងបិទសាលាមួយរយៈ តែបែរជាឱ្យធ្វើសង្ក្រាន។ ម្យ៉ាងទៀតបើសិនជាយើងធ្វើ ក៏ត្រូវការចំណាយលុយកាក់ដើម្បីធ្វើ ដូចនេះយើងត្រូវគិតទុកឱ្យហើយគឺសម្រេចផ្អាកការរៀបចំអង្គរសង្ក្រាន្តនៅឆ្នាំនេះទៀត»។

លោកនាយករដ្ឋមន្ត្រីបានបន្តទៀតថា ការប្រមូលផ្តុំកម្លាំងមនុស្សដើម្បីរៀបចំនឹងមានការលំបាកដោយសារនៅពេលដែលករណីជំងឺនេះ លោកមិនចង់ឱ្យមានការប្រមូលផ្តុំទេ។

ជាមួយគ្នានេះដែររាជរដ្ឋាភិបាលកម្ពុជាក៏បានសម្រេចផ្អាកនូវកម្មវិធីជាច្រើនទៀត ទាក់ទងនឹងការប្រមូលផ្តុំមនុស្សច្រើន ដូចជាការប្រគុំតន្ត្រីគ្រប់ប្រភេទក្នុងរាជធានី និងបណ្តាខេត្តផ្សេងៗ កម្មវិធីគ្រប់សាសនាទាំងអស់ ការទស្សនាសារមន្ទីរនានា ព្រះបរមរាជវាំង និងកម្មវិធីជាច្រើនទៀត ដើម្បីបង្ការការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលរហូតមកដល់ពេលនេះ ប្រទេសកម្ពុជាមានអ្នកឆ្លងរហូតដល់៩៨នាក់គិតត្រឹមថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០៕

## ស្ថានីយ៍ស្រោចស្រព វ៉ាដាទីពីរ នឹងលេចជារូបរាងនៅឆ្នាំក្រោយ

*ដោយ ៖ ផល សុផានិត*

អ្នកនាំពាក្យក្រសួងធនធានទឹក និងឧតុនិយម បានឱ្យដឹងថា នៅឆ្នាំ២០២១ខាងមុខនេះ នឹងចាប់ផ្តើមដំណើរការគម្រោងសាងសង់ស្ថានីយស្រោចស្រពទឹក "វ៉ាដា" ទី២ នៅខេត្តកំពង់ធំ ដែលគ្រោងចំណាយថវិកាប្រមាណ៧លានដុល្លារ។

លោក ចាន់ យុត្ថា អ្នកនាំពាក្យក្រសួងធនធានទឹក និងឧតុនិយម ថ្លែងឡើងក្នុងសន្និសីទសារព័ត៌មានស្តីពី "វឌ្ឍនភាព និងទិសដៅការងារបន្ត របស់ក្រសួងធនធានទឹក និងឧតុនិយមថា ដើម្បីបង្កើនការស្រោចស្រប់ទឹកជូនប្រជាពលរដ្ឋកាន់តែច្រើន ឆ្នាំ២០២១ខាងមុខនេះ ក្រសួងធនធានទឹកនឹងចាប់ផ្តើមគម្រោងទី២សាងសង់ស្ថានីយស្រោចស្រប់ទឹក "វ៉ាដា" នៅខេត្តកំពង់ធំ ដោយសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ហៅកាត់ ADB ដែលគ្រោងចំណាយថវិកាប្រមាណ៧លានដុល្លារ។

លោកបានលើកឡើងឱ្យដឹងទៀតថា សមិទ្ធផល រួមទាំងទិសដៅការងារបន្ត របស់ក្រសួងក្រសួងគឺជាស្នូល ជំរុញគោលនយោបាយអភិបាលកិច្ចល្អ ឱ្យកាន់តែមានប្រសិទ្ធភាព ឆ្លើយតបទៅ នឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល។

លោក ចាន់ យុត្ថា បានបន្តថា ក្រសួងធនធានទឹកនឹងបន្តកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាមិត្ត ជាដៃគូអភិវឌ្ឍ ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាការប្រែប្រួលអាកាសធាតុជាដើម។

បន្ថែមលើសពីនេះ ក្រសួងធនធានទឹក និងឧតុនិយម បានរៀបចំផែនការ ៣ឆ្នាំរំកិល សម្រាប់បំពេញដល់តំបន់ដែលខ្វះខាតទឹកដើម្បីប្រើប្រាស់ និងស្រោចស្រប់ដំណាំកសិកម្មរបស់ប្រជាពលរដ្ឋផងដែរ៕

# រដ្ឋាភិបាលប្រកាសបិទ មន្ត្រីសហជីពប្រកាសស្នើសុំ

**រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសុខាភិបាលបានប្រកាសសម្រេចបិទកាស៊ីណូ KTV ក្លឹបកំសាន្ត Beer garden រោងភាពយន្ត និងសារមន្ទីរនៅទូទាំងប្រទេស ស្របពេលដែលស្ថានភាពនៃការរីករាលជំងឺកូវីដ១៩កំពុងតែធ្វើឱ្យថ្នាក់ដឹកនាំ និងប្រជាពលរដ្ឋនៅក្នុងសកលលោកមានការបារម្ភទាំងបញ្ហាសុខភាព និងប្រាក់ចំណូល។**



*ក្រសួងសុខាភិបាលបានប្រកាសសម្រេចបិទកាស៊ីណូ KTV ក្លឹបកំសាន្ត Beer garden រោងភាពយន្ត និងសារមន្ទីរនៅទូទាំងប្រទេស។* ***រូបភាព៖ ក្រសួងសុខាភិបាល***

*ដោយ ៖ អមរិន្ទ្រ ដានុត*

ការសម្រេចបិទនេះ ត្រូវបានអនុវត្តចាប់ពីចុងខែមីនារហូតដល់ស្ថានភាពនៃជំងឺកូវីដ-១៩បានធូរស្រាលឡើងវិញ។

ការបិទដំណើរការអាជីវកម្មទាំងនេះត្រូវបានប្រជាពលរដ្ឋទូទៅភាគច្រើនមានការសាទរ ប៉ុន្តែមន្ត្រីសហជីពដែលធ្វើការផ្ទាល់ និងដោយប្រយោលហាក់មានការបារម្ភពីជីវភាពរបស់បុគ្គលិក និយោជិតដែលជាអ្នកធ្វើការ និងបានចំណូលពីកន្លែងនោះដើម្បីផ្គត់ផ្គង់ក្នុងគ្រួសារ។

លោក ប៉ាវ ស៊ីណា ប្រធានសម្ព័ន្ធសហជីពចលនាកម្មករ បានលើកឡើងថា ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ បានធ្វើឱ្យបុគ្គលិកនិយោជិត បំរើការងារនៅតាមក្លឹបកំសាន្ត (ខារ៉ាអូខេ) និងនៅតាមរោងភាពយន្តនានាក្នុងប្រទេសកម្ពុជា រាប់ពាន់នាក់ ត្រូវបានផ្អាកការងារជាបណ្តោះអាសន្នដោយគ្មានកំណត់ ពេលវេលា គឺពឹងផ្អែកលើស្ថានភាពជំងឺកូវីដ-១៩ ។

លោកបានបន្ថែមថា ច្បាស់ណាស់ថា ការផ្អាកការងារនេះ និងធ្វើឱ្យបុគ្គលិកនិយោជិតទាំងអស់នៅក្នុងវិស័យនេះ និងរងផលប៉ះពាល់ធ្ងន់ធ្ងរចំពោះសេដ្ឋកិច្ចក្រុមគ្រួសាររបស់ពួកគាត់។

លោក ប៉ាវ ស៊ីណា បានថ្លែងដោយមានលាយទាំងសំណើចផងថា៖ «ក្នុងកាលៈទេសៈដ៏លំបាកនេះ ខ្ញុំសូមសំណូមពរដល់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ជួយឧបត្ថម្ភដោយផ្តល់ជាកញ្ចប់ថវិការកំរិតណាមួយទៅដល់បងប្អូនបុគ្គលិក និយោជិត ដើម្បីជួយសម្រាលនូវទុក្ខលំបាករបស់ពួកគាត់»។

ជាមួយនេះដែរ លោកក៏បានអំពាវនាវដល់កម្មករនិយោជិត ឱ្យមានការប្រុងប្រយ័ត្នខ្ពស់ ដើម្បីបញ្ចៀសពីការឆ្លងជំងឺកូវីដ-១៩ ស្របពេលដែលតួលេខនៃអ្នកឆ្លងនៅប្រទេសកម្ពុជាកើនដល់៤៧ករណីគិតត្រឹមថ្ងៃទី១៩ខែមីនា និងបានរីករាលដាលដល់បណ្តារាជធានី-ខេត្តមួយចំនួនផងដែរ។

ទាក់ទងនឹងការបារម្ភនេះដែរ សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF) ក៏បានចេញសេចក្តីថ្លែងការណ៍ស្តីពីការបិទKTV និងរោងភាពយន្តនៅទូទាំងប្រទេសដោយសារតែជំងឺកូវីដ-១៩នេះដែរ។

សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា ស្វាគមន៍ចំពោះចំណាត់ការរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការគិតគូរពីការបញ្ចៀសការរីករាលដាលនៃជំងឺកូវីដ-១៩ដោយសម្រេចបិទ KTV ក្លឹបកំសាន្ត រោងភាពយន្ត និងសារមន្ទីរ រហូតស្ថានភាពមានការធូរស្បើយវិញ។

> ក្នុងកាលៈទេសៈដ៏លំបាកនេះ ខ្ញុំសូមសំណូមពរដល់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ជួយឧបត្ថម្ភដោយផ្តល់ជាកញ្ចប់ថវិការកំរិតណាមួយទៅដល់បងប្អូនបុគ្គលិក និយោជិត ដើម្បីជួយសម្រាលនូវទុក្ខលំបាករបស់ពួកគាត់

លោកស្រី អ៊ូ ទេពផល្លីន ប្រធានសហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា រំពឹងថាចំណាត់ការនេះនឹងអាចធ្វើឱ្យកម្ពុជាការពារបានពីជំងឺដ៏កាចសាហាវនេះ ប៉ុន្តែយ៉ាងណាមិញ លោកស្រីដែលបាន និងកំពុងធ្វើការជាមួយកម្មករ និយោជិតនៅក្នុងវិស័យសេវាកម្ម កម្សាន្ត មើលឃើញថា ស្ថានភាពនេះនឹងធ្វើឱ្យប៉ះពាល់ជីវភាពរស់នៅរបស់កម្មករ និយោជិតដែលកំពុងបំរើការងារនៅក្នុងគ្រឹះស្ថាន KTV និងរោងភាពយន្តដែលមានចំនួនប្រមាណជា៨ម៉ឺននាក់នៅទូទាំងប្រទេស ដែលភាគច្រើនគឺជាស្ត្រី។

លោកស្រី អ៊ូ ទេពផល្លីន បានលើកឡើងថា៖ «ក្រៅពីគិតគូរដល់សុខភាពរបស់កម្មករក៏ដូចជាប្រជាពលរដ្ឋទូទៅ សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា សូមស្នើដល់រាជរដ្ឋាភិបាលកម្ពុជាពិនិត្យមើលនូវលទ្ធភាពក្នុងការដោះស្រាយស្ថានភាពមួយចំនួនជាអាទិភាពដែលជាតម្រូវការមូលដ្ឋានរបស់កម្មករ និយោជិតរបស់យើងដូចជាផ្នែកហិរញ្ញវត្ថុក្នុងការផ្គត់ផ្គង់លើការហូបចុកប្រចាំថ្ងៃ កន្លែងស្នាក់នៅ (ផ្ទះជួល) ក្នុងអំឡុងពេលដែលពួកគាត់មិនមានប្រាក់ចំណូល»។

ប្រធានសហជីពរូបនេះបានបន្តទៀតថា រដ្ឋាភិបាលគួរពិនិត្យទៅលើការព្យាបាលក្នុងករណីដែលពួកគាត់ ឬសមាជិកគ្រួសាររបស់ពួកគាត់មានជំងឺ ដោយសារកម្មករ និយោជិតក្នុងវិស័យនេះមិនទាន់បានចុះបញ្ជីក្នុងបេឡាជាតិរបបសន្តិសុខសង្គមនៅឡើយ និងស្នើឱ្យរដ្ឋាភិបាលពិនិត្យមើលលើការពន្យាពេលសងបំណុលទៅធនាគារ ឬមីក្រូហិរញ្ញវត្ថុក្នុងអំឡុងពេលនេះ។

ដោយសារតែឃើញមានប្រជាពលរដ្ឋមួយចំនួននៅតែមានការភ័យ និងបារម្ភខ្លាំង ចំពោះការរីករាលដាលនៃជំងឺកូវីដ១៩នេះ ក្រសួងសុខាភិបាលបានអំពាវនាវឱ្យប្រជាពលរដ្ឋ ត្រូវមានភាពនឹងនរក្នុងចិត្ត កុំមានការភ័យខ្លាច និងត្រូវជឿទុកចិត្តលើវិធានការរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំង នឹងជំងឺកូវីដ១៩នេះ។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាលបានឱ្យដឹងថា ដើម្បីបញ្ចៀសនូវការចម្លងជំងឺកូវីដ១៩ ក្នុងសហគមន៍ជាយថាហេតុ រាជរដ្ឋាភិបាល បានឱ្យក្រសួងសុខាភិបាល សហការជាមួយកងកម្លាំងសុខាភិបាល នៃកងយោធពលខេមរភូមិន្ទ និងកងកម្លាំងសុខាភិបាល នៃនគរបាលជាតិ រួមគ្នាប្រយុទ្ធនឹងជំងឺកូវីដ១៩នេះ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ក្នុងនោះដែរប្រជាពលរដ្ឋទាំងអស់ត្រូវរក្សាអនាម័យដៃ ខ្លួនប្រាណ ចំណីអាហារ និងបរិស្ថានជុំវិញខ្លួនឱ្យបានជាប់ជាប្រចាំជានិច្ច៕



*លោក ប៉ាវ ស៊ីណា ប្រធានសម្ព័ន្ធសហជីពចលនាកម្មករ។* ***រូបភាព៖ ហ្វេសប៊ុក***



*លោកស្រី អ៊ូ ទេពផល្លីន ប្រធានសហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា។* ***រូបភាព៖ វិទ្យុបារាំងអន្តរជាតិ***







*ក្រុមប្រឹក្សា ឃុំសង្កាត់ មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធខេត្តបាត់ដំបង ក្នុងពិធីជួបសំណេះសំណាលសម្តេចតេជោ ហ៊ុន សែន។* ***រូបភាព៖ ហ្វេសប៊ុកនាយករដ្ឋមន្ត្រី***



*លោកជំទាវ បាន ស្រីមុំ អ្នកតំណាងរាស្ត្រមណ្ឌលខេត្តប៉ៃលិននៅក្នុងកិច្ចប្រជុំសភានាពេលកន្លងមក។* ***រូបភាព៖ ហ្វេសប៊ុកនាយករដ្ឋមន្ត្រី***

# ស្ត្រីនៅក្នុងជួរមន្ត្រីរាជការ មានជាង៤០ភាគរយ

*ដោយ ៖ អរិយបុត្រ*

រហូតមកដល់ពេលនេះគេដឹងថា នៅក្នុងជួរមន្ត្រីរាជការដែលកំពុងបម្រើការនៅតាមស្ថាប័នរាជការ នានានៅក្នុងប្រទេសកម្ពុជាតាំងពីថ្នាក់ក្រោមជាតិរហូតដល់ថ្នាក់ដឹកនាំ មានប្រមាណជា៤១ភាគរយ។ នេះបើតាមរបាយការណ៍នៃការកត់ត្រាទុកដោយក្រុមប្រឹក្សាជាតិដើម្បីស្ត្រី ។

របាយការណ៍ដែលគេបានកត់ត្រាកាលពីឆ្នាំ២០១៩ បានបង្ហាញថា សមភាពយ៉េនឌ័រ ជាសកម្មភាពអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយនៅទូទាំងប្រទេសកម្ពុជាមានមន្ត្រីរាជការសរុប ចំនួនប្រមាណជា ២១៨.៦៣៥ រូប នៅក្នុងនោះមាន មន្ត្រីរាជការស៊ីវិលជាស្ត្រីចំនួន ៨៩.៥៣២រូប ឬ៤១ភាគរយ នៃចំនួនមន្ត្រីសរុបដែលកំពុងតែបម្រើការងារ។

ប្រភពដដែលបានឱ្យដឹងថា នៅក្នុងចំណោមមន្ត្រីរាជការសរុបទាំងអស់ មានចំនួន ៤៣.៨៤៩ រូបជាមន្ត្រីនៅកម្រិតជាតិ នៅក្នុងនោះ ៣១ភាគរយជាស្ត្រី មន្ត្រីចំនួន ១៧៤.៧៨៦រូបកំពុងតែបម្រើការនៅកម្រិតថ្នាក់ក្រោមជាតិ ក្នុងនោះមន្ត្រី ៧៥.៨៦៨ រូប គឺជាស្ត្រី។

របាយកាណ៍ដដែលនេះបានឱ្យដឹងថា ប្រទេសកម្ពុជាមានសមាជិកព្រឹទ្ធសភាជាស្ត្រីមានចំនួន១០រូប, សមាជិកសភាជាស្ត្រីមានចំនួន២៦រូប, ឧបនាយករដ្ឋមន្ត្រីមានមួយរូប, រដ្ឋមន្ត្រីជាស្ត្រី៣រូប, រដ្ឋលេខាធិការជាស្ត្រីចំនួន ៥៣រូប, អនុរដ្ឋលេខាធិការជាស្ត្រីចំនួន ៧០រូប, អភិបាលខេត្តជាស្ត្រីមាន ១រូប, អភិបាលរងខេត្តជាស្ត្រីចំនួន ២៦រូប, អភិបាលស្រុក, ក្រុង , ខណ្ឌ ជាស្ត្រីមានចំនួន ០៦ , អភិបាលរងខណ្ឌ,អភិបាលរងក្រុង,ស្រុក, ជាស្ត្រីមានចំនួន ១៩៤ , ចៅសង្កាត់,មេឃុំជាស្ត្រីមានចំនួន ១៣០។ នៅក្នុងស្ថាប័នតុលាការមានស្ត្រីជាចៅក្រមចំនួន ៣៧ រូប និងព្រះរាជអាជ្ញា ២៣ រូបជាស្ត្រី។

ជាទូទៅរាជរដ្ឋាភិបាលតែងតែផ្តល់តម្លៃខ្ពស់ចំពោះសមភាពយេនឌ័រនៅក្នុងជួរមន្ត្រីរាជការក៏ដូចជានៅក្នុងរចនាសម្ព័ន្ធសង្គមទូទៅរហូតដល់ទៅសង្គមគ្រួសារ ។

ជាក់ស្តែងកាលពីថ្ងៃទី ០៦ ខែ មីនា ឆ្នាំ២០២០នេះ នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានចូលរួមអបអរសាទរទិវានារីអន្តរជាតិ ៨ មីនាខួបលើកទី១០៩ បានបន្ត បង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជាបន្ថែមទៀតលើស្ត្រី។

លោកបានស្នើឱ្យគ្រប់ក្រសួងស្ថាបន័ពាកព័ន្ធ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន ព្រមទាំងប្រជាពលរដ្ឋគ្រប់រូប រួមគ្នាផ្តោតការយកចិត្តទុកដាក់ទៅលើចំណុចសំខាន់ៗមួយចំនួន ក្នុងការលើកកម្ពស់សមភាពយេនឌ័រតាមរយៈការពង្រឹងរចនាសម្ព័ន្ធស្ថាប័ន ការកំណត់វិធានការម៉ឺងម៉ាត់ និងការបង្កើតក្រុមការងារបច្ចេកទេសយេនឌ័រ។

ចំណុចទាំងនេះរួមមាន ការរក្សាចំនួនស្ត្រីក្នុងតួនាទីជាថ្នាក់ដឹកនាំនៅគ្រប់កម្រិត, ទប់ស្កាត់ និងអន្តរាគមន៍នូវអំពើហិង្សាតាមគ្រប់ទម្រង់ដោយរួមទាំងអ៊ីនធើណែត, បន្តវិនិយោគលើការសិក្សារបស់ក្មេងស្រីនៅគ្រប់កម្រិតសិក្សា, ពង្រឹង និងលើកកម្ពស់សីលធម៌សង្គមតម្លៃស្ត្រី និងគ្រួសារខ្មែរ។ល។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា រាជរដ្ឋាភិបាល បានកំពុងផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រីដែលមានចំនួនជាង ៥០ភាគរយនៃចំនួនប្រជាជនសរុប ដើម្បីឱ្យពួកគេក្លាយជាធនធានប្រកបដោយសក្តានុពលក្នុងការរួមចំណែកអភិវឌ្ឍ សង្គម និងសេដ្ឋកិច្ចជាតិ។

សម្តេចតេជោបានថ្លែងទៀតថា ទិវាអន្តរជាតិនារី ៨ មីនា គឺជាការបង្ហាញអំពីគុណសម្បត្តិគ្រប់លក្ខណៈរបស់ស្ត្រីដែលជាមាតាពិភពលោកជាមួយនឹងបាវចនា «ជួយស្ត្រីគឺជួយខ្លួនឯង» និង «សិទ្ធិស្ត្រីគឺជាសិទ្ធមនុស្ស»។

លោកស្រី និន វិមាន ជាមន្ត្រីរាជការ និងជាស្ត្រីអ្នកទេសចរមួយរូបបានថ្លែងកាលពីថ្ងៃទី០៨ ខែ មិនា នៅឆ្នេរអូឈើទាលថា ពីសម័យមុនស្ត្រីដែលមានតួនាទីធំៗគឺតិចណាស់ ភាគច្រើនគឺត្រឹមតែជាកសិករ និងជាស្ត្រីមេផ្ទះតែប៉ុណ្ណោះ ប៉ុន្តែសម័យនេះគឺខុសគ្នា។

លោកស្រីបានបញ្ជាក់ថា៖ «តាមស្ថាប័នរដ្ឋឥឡូវ ស្ត្រីដែលមានតួនាទីធំៗគឺច្រើនណាស់ ហើយប្រធានខ្ញុំក៏ជាស្ត្រីផងដែរ»។

លោកស្រីបានបន្ថែមទៀតថា នៅតាមស្ថាប័នត្រឹមតែជាប្រធានការិយាល័យ ដល់អគ្គនាយកក៏មានច្រើនដែរ ហើយ ភាគច្រើនសុទ្ធតែជាអ្នកដែលមានសមត្ថភាព ដែលខុសពីសម័យមុន ដែលមានស្ត្រីបម្រើការភាគច្រើន គឺត្រឹមតែជាគ្រូបង្រៀន និងអ្នកគ្រូពេទ្យ៕



*លោកជំទាវ បាន ស្រីមុំ អ្នកតំណាងរាស្ត្រមណ្ឌលខេត្តប៉ៃលិននៅក្នុងកិច្ចប្រជុំសភានាពេលកន្លងមក។* ***រូបភាព៖ រដ្ឋសភាជាតិ***

# វិធានការទប់ស្កាត់ផលប៉ះពាល់ដោយជំងឺ វីរុសកូរ៉ូណា ជុំទីពីរ

ប្រមុខរាជរដ្ឋាភិបាលកម្ពុជាកាលពីដើមខែ មីនា បានប្រកាសដាក់ចេញនូវវិធានការបន្ទាប់មួយទៀតដើម្បីឆ្លើយតបនឹងផលប៉ះពាល់អវិជ្ជមានដែលបណ្តាលមកពី ការរីករាលដាលនៃមេរោគ កូវីដ១៩ ដែលពិភពលោកកំពុងតែភ័យខ្លាច ដោយវិធានការថ្មីនេះគឺ ការកាត់បន្ថយចំណាយតាមក្រសួងស្ថាប័នរដ្ឋនានាចំនួន ៥០ ភាគរយដើម្បីត្រៀមទប់ទល់ការរីករាលដាលនៃកូវីដ១៩ នេះ។

*ដោយ ៖ អរិយបុត្រ*

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាបានប្រកាសថា ចាប់ពីការផ្ទុះឡើងនូវជំងឺវីរុសកូរ៉ូណា ឬ កូវីដ១៩ រហូតដល់ពេលនេះការងារអាទិភាពខ្ពស់បំផុតរបស់កម្ពុជានោះគឺការប្រយុទ្ធប្រឆាំងការរីករាលដាលរបស់វា។ លោកបានសង្កត់ធ្ងន់ថា ការកាត់បន្ថយចំណាយជាវិធានការមួយក្នុងការទប់ទល់នឹងផលប៉ះពាល់សេដ្ឋកិច្ចដែលបណ្តាលមកពីកូវីដ១៩ ដោយរាជរដ្ឋាភិបាលបានសម្រេចកាត់បន្ថយការចំណាយ ដែលមិនមែនជាបន្ទុកបៀវត្សរបស់ស្ថាប័នរដ្ឋទាំងអស់ក្នុងកម្រិត ៥០ភាគរយ លើកលែងក្រសួងការបរទេស, ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងពាណិជ្ជកម្ម ដែលកាត់បន្ថយត្រឹម២៥ភាគរយ។

លោកនាយករដ្ឋមន្ត្រីបានថ្លែងនៅក្នុងពិធីបិទសន្និបាតបូកសរុបការងារក្រសួងសុខាភិបាលនាដើមខែមីនា ឆ្នាំ២០២០ថា រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការសង្គ្រោះសេដ្ឋកិច្ចនៅក្នុងដំណាក់កាលនៃវិបត្តិកូវីដ១៩ កាលពីថ្ងៃទី ២៤ ខែកុម្ភៈ រួចហើយ ដោយបានដាក់ចេញនូវគោលនយោបាយមួយចំនួនទាក់ទងជាមួយនឹងការគាំពារទៅលើវិស័យដែលមានផលប៉ះពាល់ដូចជាវិស័យទេសចរណ៍ និងក្នុងវិស័យកាត់ដេរ។ លោកក៏បានជំរុញគណៈកម្មការគោលនយោបាយសេដ្ឋកិច្ច និងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុរៀបចំនូវផែនការដើម្បីឆ្លើយតបជាមួយបញ្ហាទាំងឡាយដែលទាក់ទងនឹងបញ្ហាសេដ្ឋកិច្ចនៅក្នុងបរិបទដែលកូវីដ១៩រីករាលដាល។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា៖ «រដ្ឋមន្ត្រីគ្រប់ក្រសួងទាំងអស់កុំសុំបង្កើនការចំណាយអ្វីទាំងអស់ ប៉ុន្តែការចំណាយទៅលើបៀវត្សមិនត្រូវបានកាត់បន្ថយទេ។ ការចំណាយចរន្តក្នុង ១ខែជាង ៤០០លានរៀលក៏មិនត្រូវកាត់បន្ថយផងដែរ។ ការកាត់បន្ថយការចំណាយនេះ គឺដើម្បីទុកបម្រុងថវិកាសម្រាប់វិស័យសុខាភិបាលក្នុងការត្រៀមការទប់ទល់ជាមួយ និងមេរោគកូវីដ១៩»។



ផ្ទាំងផ្សព្វផ្សាយចូលរួមបញ្ឈប់ការឆ្លងរាលដាលជំងឺកូវីដ១៩។ រូបភាព៖ ក្រសួងសុខាភិបាល


សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីថ្លែងក្នុងពិធីបិទសន្និបាតបូកសរុបការងារក្រសួងសុខាភិបាល។ រូបភាព៖ ហ្វេសប៊ុកនាយករដ្ឋមន្ត្រី

លោកបញ្ជាក់បន្ថែមថា សម្រាប់ការប្រយុទ្ធប្រឆាំងកូវីដ១៩នេះ បើទោះបីជាត្រូវកាត់ថវិកាពីវិស័យដទៃយកមកប៉ះប៉ូវឱ្យក្រសួងសុខាភិបាល ក៏ត្រូវតែធ្វើដែរ។

រដ្ឋមន្ត្រីក្រសួងសុខាភិបាល លោក ម៉ម ប៊ុនហេងបានប្រកាសកាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២០ ការរកឃើញជំងឺកូវីដ១៩ កើតលើខ្លួនបុរសជនជាតិខ្មែរម្នាក់អាយុ៣៨ឆ្នាំ នៅខេត្តសៀមរាប ដែលជាបុរសខ្មែរទី១ ដែលបានឆ្លងមេរោគនេះ។ បុគ្គលិកសុខាភិបាល និងអាជ្ញាធរខេត្តបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើករណីនេះ ដោយបុរសនេះត្រូវបានព្យាបាល និងដាក់ឱ្យស្ថិតនៅដាច់ដោយឡែកពីគេ ចំណែកសមាជិកក្រុមគ្រួសាររបស់គាត់ក៏បានធ្វើតេស្តរកមេរោគនេះដែរ ប៉ុន្តែលទ្ធផលអវិជ្ជមាន។ រហូតមកដល់ថ្ងៃទី២៩ ខែមីនា បុរសនោះត្រូវបានពិនិត្យឃើញថាបានជាសះស្បើយ និងបានត្រឡប់ទៅក្រុមគ្រួសាររបស់គាត់វិញដែរ។

បន្ទាប់ពីរកឃើញករណីដំបូងនេះ លោកនាយករដ្ឋមន្ត្រី បានដាក់ចេញវិធានការជាបន្ទាន់ ដោយសម្រេចបិទសាលារៀននៅទីរួមខេត្ត សៀមរាប ជាបណ្តោះអាសន្ន និងលុបចោលអង្គរសង្ក្រាន្តឆ្នាំ២០២០នេះផងដែរ។

ស្របពេលជាមួយគ្នានេះផងដែរ ក្រសួងសុខាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ នៅតែបន្តអំពាវនាវឱ្យប្រជាពលរដ្ឋប្រុងប្រយ័ត្នខ្ពស់ និងប្រកាន់ខ្ជាប់នូវការអនុវត្តវិធានការនានារបស់ក្រសួងសុខាភិបាល ដូចជា ពាក់ម៉ាសនៅពេលចាំបាច់ ត្រូវលាងដៃនឹងសាប៊ូ ឬអាល់កុល ឱ្យបានញឹកញាប់ដើម្បីការពារមេរោគកូវីដ១៩នេះជាដើម។


បុគ្គលិកសុខាភិបាលចុះតាំងបង្ហាញផ្ទាំងផ្សព្វផ្សាយអំពីការរក្សាអនាម័យប្រឆាំងនិងមេរោគកូវីដ១៩នៅតាមមូលដ្ឋាន។ រូបភាព៖ ក្រសួងសុខាភិបាល

យោងតាមរបាយការណ៍របស់អង្គការសុខភាពពិភពលោក (World Health Organization) គិតត្រឹមវេលាម៉ោងជាង២រសៀល ក្នុងថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ បានបង្ហាញថា ប្រទេស និងដែនដីជិត២១០ហើយ ដែលមានករណីឆ្លងជំងឺកូវីដ១៩ ហើយអ្នកឆ្លងបានកើនឡើងរហូតដល់ ជាង ១.២៧លានករណី ក្នុងនោះ ជិត ៧០,០០០នាក់ស្លាប់ និងប្រមាណជា ២៧ម៉ឺននាក់បានជាសះស្បើយ៕





# អ្នកសេដ្ឋកិច្ចអាស៊ាន ហាក់មើលរំលងផលប៉ះពាល់ដោយសារ COVID-19

ផលប៉ះពាល់នៃសេដ្ឋកិច្ចជាសាកលបណ្តាលមកពីជំងឺកូវីដ១៩ ប្រហែលជាត្រូវបានមើលរំលងដោយអ្នកសេដ្ឋកិច្ចអាស៊ាន ដោយសារតែការផ្ទុះនៃមេរោគនេះនៅបណ្តាប្រទេសនៅអឺរ៉ុប និងអាមេរិកលើសពីការរំពឹងគិតទុកជាមុន។



បណ្តារដ្ឋមន្ត្រីប្រទេសមកពីអាស៊ានចូលរួមក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានដែលបានធ្វើឡើងនៅទីក្រុងដាណាំង ស្ថិតនៅភាគកណ្តាលប្រទេសវៀតណាម។ រូបភាព៖ Công Thành

*ដោយ ៖ អរិយបុត្រ*

រហូតមកដល់ពេលនេះ គ្មាននរណាអាចទឹកស្មានដល់ថា ការផ្ទុះ និងរីកសាយភាពនៃមេរោគនេះក្នុងបណ្តាប្រទេសនៅអឺរ៉ុប ដែលជាអរិយប្រទេស និងជាឫសគល់នៃវេជ្ជសាស្ត្រទំនើបរបស់ពិភពលោក ធ្លាក់នៅក្នុងកម្រិតដូច្នេះឡើយ។

ជំងឺរលាកសួតប្រភេទថ្មីដែលគ្រប់គ្នាស្គាល់ថា ជំងឺកូវីដ១៩ បានឆ្លង និងរីករាលដាលនៅក្នុងប្រទេសចិនយ៉ាងគំហុក ចាប់ពីចុងខែធ្នូ ឆ្នាំ២០១៩ រហូតដល់ពេលនេះ ដោយបានរីករាលដាលដល់ប្រទេសមួយចំនួននៅអាស៊ី ដោយរួមទាំងអាស៊ាន ដែលគេដឹងថាជាដៃគូពាណិជ្ជកម្ម ទេសចរណ៍ និងវិនិយោគទុនដ៏ចម្បងរបស់ចិន រហូតប្រទេសនានា នៅអាស៊ានបានចេញនូវវិធានការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃមេរោគនេះ ហើយនឹងវិធានចំពោះសេដ្ឋកិច្ចផងដែរ ប៉ុន្តែផលប៉ះពាល់ពេលនេះ វាអាចហួសពីការរំពឹងទុក ដោយសារតែអឺរ៉ុប និងអាមេរិក ដែលជាទីផ្សារធំ និងជាដៃគូពាណិជ្ជកម្មដ៏ចម្បងមួយរបស់អាស៊ានដែរនោះ ក៏កំពុងតែរងនូវផលប៉ះពាល់ដ៏ធំ។

ថ្មីៗនេះ ទីភ្នាក់ងារសារព័ត៌មានវៀតណាមបានរាយការណ៍ថា រដ្ឋមន្ត្រីសេដ្ឋកិច្ចនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា អាស៊ាន បានចេញសេចក្តីថ្លែងការណ៍មួយស្តីពីការពង្រឹងភាពធន់ផ្នែកសេដ្ឋកិច្ចរបស់អាស៊ានក្នុងការឆ្លើយតបទៅនឹងការផ្ទុះឡើងនៃវីរុសថ្មី COVID-១៩ ។

ប្រភពដដែលបានរាយការណ៍ថា ក្រោយកិច្ចប្រជុំលើកទី ២៦ របស់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានដែលបានធ្វើឡើងនៅទីក្រុងដាណាំងភាគកណ្តាលរបស់ប្រទេសវៀតណាម បានបញ្ជាក់ថា រដ្ឋមន្ត្រីទាំងអស់ព្រមទទួលយកសកម្មភាពរួមមួយ ដើម្បីកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ចនៃការផ្ទុះឡើងនូវមេរោគ ដោយមើលឃើញពីផលប៉ះពាល់អវិជ្ជមាននៃការផ្ទុះឡើងលើសេដ្ឋកិច្ចរួម មានវិស័យទេសចរណ៍ ផលិតកម្ម ការលក់រាយ និងផ្នែកសេវាកម្មដទៃទៀត ដោយរួមទាំង ការរំខានដល់ការផ្គត់ផ្គង់ និងទីផ្សារហិរញ្ញវត្ថុផងដែរ។

សេចក្តីថ្លែងការណ៍ដដែលបាននិយាយថា រដ្ឋជាសមាជិកនឹងនៅតែប្តេជ្ញារក្សាទីផ្សារអាស៊ានបើកចំហរសម្រាប់ពាណិជ្ជកម្ម និងការវិនិយោគ ពង្រឹងការចែករំលែក សម្របសម្រួលព័ត៌មានក្នុងតំបន់ក៏ដូចជាការសហការគ្នា ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមខាងសេដ្ឋកិច្ចដែលបណ្តាលមកពីការផ្ទុះឡើងនេះ។

បណ្តារដ្ឋមន្ត្រីអាស៊ានបានឯកភាពថា ការរឹតត្បិតវិធានការប្រឆាំងនឹងចលនាឆ្លងកាត់ព្រំដែន គួរតែផ្អែកលើការពិចារណាសុខភាពសាធារណៈ ហើយពាណិជ្ជកម្មនៅក្នុងតំបន់មិនគួរត្រូវបានហាមឃាត់ដោយមិនចាំបាច់ឡើយ។

វិធានការផ្សេងទៀតដែលត្រូវបានកត់សម្គាល់នៅក្នុងសេចក្តីថ្លែងការណ៍រួម មានការពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ានជាមួយដៃគូខាងក្រៅ និងអភិវឌ្ឍន៍ការកសាងវេទិកាសម្រួលពាណិជ្ជកម្មដែលមានស្រាប់នៅក្នុងអាស៊ាន។

នេះគឺជាវិធានការដែលរដ្ឋមន្ត្រីអាស៊ានបានដាក់ចេញរួមគ្នា ឆ្លើយតបនឹងបញ្ហារួម ហើយ ប្រទេសនានាក៏មានផែនការ និងការបម្រុងផ្សេងៗទៀត ដើម្បីការពារនូវសេដ្ឋកិច្ចរបស់ប្រទេសរៀងៗខ្លួន ដោយសារការផ្ទុះនេះគឺលើសពីការរំពឹងទុកវាមានស្ថានភាពអាក្រក់ដល់ថ្នាក់នេះ នៅក្នុងប្រទេសរីកចម្រើនដូចជានៅសហរដ្ឋអាមេរិក និងអឺរ៉ុបជាដើម។

> ផលប៉ះពាល់ពេលនេះ វាអាចហួសពីការរំពឹងទុក ដោយសារតែអឺរ៉ុប និងអាមេរិកដែលជាទីផ្សារធំ និងជាដៃគូពាណិជ្ជកម្ម ដ៏ចម្បងមួយរបស់អាស៊ាន ដែរនោះ ក៏កំពុងតែរងនូវផលប៉ះពាល់ដ៏ធំ។



ផលប៉ះពាល់លើផ្សារភាគហ៊ុន (ថ្ងៃទី២៧ ខែមីនា) បានធ្លាក់ចុះ ចាប់តាំងពីការផ្ទុះឡើងនៃការរីករាលដាលមេរោគកូវីដ១៩។ រូបភាព៖ Bloomberg



អត្រានៃការរីករាលដាលមេរោគកូវីដ (គិតត្រឹមថ្ងៃទី៣១ ខែមីនា)។ សហរដ្ឋអាមេរិកស្ថិតនៅលើតារាង។ រូបភាព៖ Financial Times

គិតមកត្រឹមថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ បានបង្ហាញថា ប្រទេស និងដែនដីជិត២១០ហើយ ដែលមានករណីឆ្លងជំងឺកូវីដ១៩ ហើយអ្នកឆ្លងបានកើនឡើងរហូតដល់ ជាង១.២៧លានករណី ក្នុងនោះ ជិត៧០,០០០នាក់ស្លាប់ និងប្រមាណជា២៧ម៉ឺននាក់បានជាសះស្បើយ។ នៅប្រទេសចិន ដែលជាស្នូលនៃ ការផ្ទុះមេរោគនេះ គឺមានសញ្ញាថយចុះ ដោយអត្រាឆ្លងថ្មីគឺមានត្រឹមតែ ២០ ករណីប៉ុណ្ណោះ ខណៈដែលអត្រា ជាសះស្បើយគឺវាមានរហូតដល់ជាង ៦០.០០០ នាក់ ហើយ ប៉ុន្តែវាកំពុងតែមាននិន្នាការកើនឡើងនៅ អឺរ៉ុបនិង សហរដ្ឋអាមេរិក ។

យោងទៅតាមរបាយការណ៍របស់អង្គការសុខភាពពិភពលោក មេរោគនេះបានឆ្លងរីករាលដាលដល់មនុស្ស សរុបចំនួន ១.២១៤.៩៧៣ នាក់ ហើយវាបានសម្លាប់មនុស្សសរុបចំនួនរហូតដល់ ៦៧.៨៤១ នាក់ ដោយការចម្លងនៅកាត់ទ្វីបអឺរ៉ុបមានចំនួនសរុបប្រមាណជា ៦៥៥.៣៣៩ នាក់ នៅអាមេរិក មានចំនួន ៣៥២.៦០០ នាក់នៅតំបន់ប៉ាស៊ីហ្វិកខាងលិច មាន ១១២.៥៧៨ នាក់ នៅតំបន់មេឌីទែរ៉ាណេ ខាងកើតមានចំនួន ៧៧.៣៥៩ នាក់ នៅតំបន់អាស៊ីអគ្នេយ៍យើងនេះ គឺមាន ៩.១៣២ នាក់ និង នៅអាហ្វ្រិកចំនួន ៦.៩៨៦ នាក់៕

# ពលរដ្ឋមានការព្រួយបារម្ភរឿងទំនិញឡើងថ្លៃ ក្រោយបិទព្រំដែនភាគខាងកើត

*ដោយ ៖ អរិយបុត្រ*

ប្រជាពលរដ្ឋកម្ពុជាមួយចំនួនកំពុងតែមានការព្រួយបារម្ភរឿងការប្រកាសបិទព្រំដែនទៅវិញទៅមករបស់ប្រទេសកម្ពុជា និងវៀតណាម ក្រោយពេលដែលពិភពលោកកំពុងតែរងគ្រោះនឹង ការរីករាលដាលនៃជំងឺកូវីដ១៩។



*សកម្មភាពអាជីវករក្នុងផ្សារមួយក្នុងរាជធានីភ្នំពេញ។ **រូបភាព៖ ស៊ីអេសស៊ី***

លោក សឿន វណ្ណា ប្រជាពលរដ្ឋវ័យ ៤៥ឆ្នាំ បានឱ្យដឹងថា ទំនិញនឹងកាន់តែឡើងថ្លៃនៅពេលប្រទេសទាំងពីរ(កម្ពុជា និងវៀតណាម) បិទព្រំដែន។

លោកបានបន្តថា រយៈពេលប៉ុន្មានថ្ងៃនេះ ទំនិញនៅតាមទីផ្សារហាក់ឡើងថ្លៃខ្លាំង ជាពិសេស គឺពពួកទំនិញធ្វើអនាម័យ និងស្បៀងអាហារ។

លោកបានបញ្ជាក់ថា៖ «ទំនិញតាំងពីទឹកលាងដៃ គ្រឿងកំប៉ុង រហូតដល់ត្រីសាច់ និង បន្លែគឺឡើងថ្លៃទាំងអស់ ហើយកន្លែងខ្លះអស់ពីស្តុកថែមទៀតផង ចុះបើបិទព្រំដែន ទៀតមិនដឹងម៉េចទេ»។

អ្នកស្រី ហេង និមល ដែលជាស្ត្រីមេផ្ទះមួយរូប បាននិយាយយ៉ាងខ្លីនៅពេលអ្នកស្រីកំពុងធ្វើដំណើរមកពីផ្សារអូរឫស្សីថា ទំនិញឥឡូវនេះដូចជាឡើងថ្លៃហួសហេតុ។ គាត់បានឱ្យដឹងថា ថ្លៃម្ហូបឥឡូវឡើងថ្លៃសឹងតែគ្រប់មុខ តាំងពីត្រី សាច់ បន្លែ គ្រឿងទេស ចាប់តាំងពីផ្ទុះមេរោគកូរ៉ូណា (កូវីដ១៩)មក។

អ្នកស្រី ហេង និមលបានលើកឡើងថា៖ «មិនដឹងម៉េចម៉ាទៀតទេពេលវៀតណាមបិទព្រំដែនបែបនេះ ពីព្រោះល្បីថា ទំនិញត្រី សាច់ និងគ្រឿងទេស របស់ប្រើប្រាស់ភាគច្រើនមកពីវៀតណាម ស្រាប់ផង»។

លោក សៀង ថៃ អ្នកនាំពាក្យក្រសួងពាណិជ្ជកម្ម មិនអាចទំនាក់ទំនងបាន ប៉ុន្តែគេបានដឹងថា រហូតមកដល់ពេលបច្ចុប្បន្ននេះ វៀតណាម គឺជាទីផ្សារនាំចូលទំនិញសំខាន់ៗជាច្រើន របស់កម្ពុជា រាប់ចាប់តាំងពីគ្រឿងទេស បន្លែ ផលិតផលពីជលផល និងសំភារៈប្រើប្រាស់ជាច្រើនប្រភេទទៀត។

ពាក់ព័ន្ធនឹងការបិទច្រកព្រំដែននេះ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំវៀតណាម កាលពីថ្ងៃទី១៨ ខែមីនា បានឱ្យដឹងថា រដ្ឋាភិបាលវៀតណាមបានចេញសេចក្តីសម្រេចស្តីពីការគ្រប់គ្រងការចេញ-ចូលសម្រាប់ជនបរទេសដោយរួមមានចំនុចមួយចំនួនដូចជា ផ្អាកការផ្តល់ទិដ្ឋាការបណ្តោះអាសន្នដល់ជនបរទេសទាំងអស់ចូលវៀតណាមរយៈពេល ៣០ថ្ងៃ ដែលត្រូវអនុវត្តចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០។ អ្នកដែលទទួលបានការលើកលែងទិដ្ឋាការ (ជនជាតិវៀតណាម និងគ្រួសារអ្នកជំនាញការ និងអ្នកជំនួញ) ត្រូវបង្ហាញវិញ្ញាបនប័ត្របញ្ជាក់ពីសុខភាពថា គ្មានជំងឺកូវីដ១៩ ចេញដោយអាជ្ញាធរមូលដ្ឋាននៃប្រទេសដែល

> …ពេលវៀតណាមបិទព្រំដែនបែបនេះ ពីព្រោះល្បីថា ទំនិញត្រី សាច់ និងគ្រឿងទេស របស់ប្រើប្រាស់ភាគច្រើនមកពីវៀតណាមស្រាប់ផង។

ពួកគេរស់នៅ ហើយត្រូវមានការយល់ព្រមជាមុនពីអាជ្ញាធរវៀតណាម មុនពេលមកដល់វៀតណាម។ អ្នកដំណើរចូលវៀតណាមទាំងអស់នឹងទទួលការពិនិត្យសុខភាព និងវិធានការបង្ការផ្សេងទៀត ឬការដាក់ឱ្យនៅដាច់ដោយឡែកស្របតាមបទបញ្ជារបស់វៀតណាម និងចំនុចចុងក្រោយ ការដាក់ឱ្យនៅដាច់ដោយឡែកក្នុងទ្រង់ទ្រាយធំនៅទីតាំងដែលបានរៀបចំទុក និងអនុវត្តចំពោះអ្នកដំណើរមកពីសហរដ្ឋអាមេរិកអឺរ៉ុប និងអាស៊ាន។ បំរាមទាំងនេះ មិនមាននិយាយអំពីបញ្ហាទំនិញឆ្លងកាត់ព្រំដែននៃប្រទេសទាំងពីរនេះទេ។

ឆ្លើយតបនឹងការសម្រេចនេះ ខាងកម្ពុជាក៏បានដាក់ចេញនូវវិធានការតបតវិញដែរ ដើម្បីបង្ការខ្លួន ជុំវិញការរីករាលដាលជំងឺកូវីដ១៩នេះ ដោយបញ្ជាក់អំពីការផ្អាកការធ្វើដំណើរឆ្លងកាត់ព្រំដែនមួយរយៈ ដោយមិនអនុញ្ញាតឱ្យប្រជាជនប្រទេសទាំងពីរឆ្លងកាត់ឡើយ។ ការអនុវត្តវិធានការនេះ ត្រូវធ្វើឡើងចាប់ពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០នេះមក។

ការសម្រេចផ្អាកការធ្វើដំណើរតាមច្រកព្រំដែនរវាងប្រទេសទាំងពីរនេះ ធ្វើឡើងក្នុងគោលបំណងចៀសវាងមានការលំបាកកើតឡើងនៅតាមច្រកព្រំដែនប្រទេសទាំងពីរ ដោយយោងលើការកើនឡើងយ៉ាងគំហុក នូវការរកឃើញករណីឆ្លងវីរុសកូវីដ១៩ ខណៈដែលប្រទេសវៀតណាម បានដាក់កម្រិតលើការធ្វើដំណើរ ដែលតម្រូវឱ្យមានការដាក់នៅដោយឡែកពីគេរយៈពេល ១៤ថ្ងៃ ចំពោះអ្នកដំណើរមកពីប្រទេសសមាជិកអាស៊ាន រួមទាំងជនជាតិវៀតណាមដែលវិលត្រឡប់ចូលស្រុកវិញផងដែរ។

ប្រភពដដែលបានកំណត់ថា ការធ្វើដំណើរចូលប្រទេសកម្ពុជាដោយពលរដ្ឋវៀតណាម និងការធ្វើដំណើរចូលប្រទេសវៀតណាមដោយពលរដ្ឋកម្ពុជា តាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាសទាំងអស់ នឹងត្រូវផ្អាកជាបណ្តោះអាសន្ន ចាប់ពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០។ វិធានការនេះមានគោលបំណងបញ្ចៀសនូវការលំបាកចំពោះពលរដ្ឋវៀតណាម ក៏ដូចជាពលរដ្ឋកម្ពុជា ដែលតម្រូវឱ្យបង្ខាំងខ្លួននៅដាច់ពីគេ ក្រោយពីបានធ្វើដំណើរពីប្រទេសកម្ពុជា ចូលទៅវៀតណាម។

ក្រសួងការបរទេសកម្ពុជា បានបន្ថែមថា វិធានការខាងលើនេះមិនត្រូវបានអនុវត្តចំពោះពលរដ្ឋវៀតណាម និងពលរដ្ឋកម្ពុជា ដែលកាន់លិខិតឆ្លងដែនការទូត និងផ្លូវការទេ ហើយក៏មិនប៉ះពាល់ដល់ការចរាចរណ៍ទំនិញនោះដែរ។

ក្រសួងការបរទេសបានអះអាងថា ភាគីកម្ពុជាស្នើឱ្យអាជ្ញាធរមូលដ្ឋាននៃប្រទេសទាំងពីរ ធ្វើការរួមគ្នា ដើម្បីសម្របសម្រួល និងធានាថា ការដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែនរួម អាចអនុវត្តដោយគ្មានការរាំងស្ទះ។

ពាក់ព័ន្ធនឹងតម្លៃនៃម្ហូបអាហារឡើងថ្លៃនេះវិញ សមាគមអ្នកចិញ្ចឹមសត្វកម្ពុជា បានអះអាងថា តម្រូវការកំពុងតែធ្វើឱ្យអ្នកចិញ្ចឹមសត្វនៅក្នុងស្រុកមានទឹកមាត់ខ្លះៗឡើងវិញ ជាពិសេស គឺ សាច់ជ្រូក ក្រោយពីប្រឈមមុខខ្លាំងពេលរាតត្បាតជំងឺប៉េសជ្រូក កាលពីប៉ុន្មានខែមុននេះ។

សមាគមអ្នកចិញ្ចឹមសត្វកម្ពុជា បានរាយការណ៍ថា តម្រូវការទាំងសាច់ស្រស់ និងសាច់កែច្នៃ គឺមានការកើនឡើង ហើយជាពិសេសគឺសាច់ជ្រូករស់បានឡើងថ្លៃដល់ទៅ ១២.០០០ ទៅ ១៣.០០០រៀលនៅក្នុងមួយគីឡូក្រាម ហើយតម្លៃសាច់ជ្រូកនៅលើទីផ្សារគឺមានតម្លៃចន្លោះពី ៣៥.០០០ទៅ ជាង ៤០.០០០ រៀល៕







*រូបភាព៖ ស៊ីអេសស៊ី*

# វិស័យសូត្រ នៅកម្ពុជាត្រូវបានស្តារឡើងវិញ

*ដោយ ៖ ផល សុផានិត*

សហគមន៍តម្បាញមួយដែលស្ថិតនៅក្នុងភូមិកោះតូច ឃុំកោះឧញ៉ាតី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល សហគមន៍នេះ បញ្ចូលទាំងការដាំរុក្ខជាតិមន និងការចិញ្ចឹមដង្កូវនាងផលិតសរសៃសូត្រសម្រាប់ត្បាញ។

ម្ចាស់រមណីដ្ឋានចំការស្នេហ៍ និងជាប្រធានសហគមន៍ផ្ទាល់ លោក រិន ណារ៉ាន់ បាននិយាយថា ក្នុង១ខែ សហគមន៍នេះអាចផលិតសូត្របានត្រឹមតែជាង១គីឡូក្រាម ដូច្នេះយើងតែងតែត្រូវការសូត្រដែលនាំចូលពីប្រទេសជិតខាងបន្ថែមទៀត ក្នុងរង្វង់មធ្យម ៥០០ គីឡូក្រាម សម្រាប់រយៈពេល១ឆ្នាំ។

លោក រិន ណារ៉ាន់ បានរៀបរាប់អំពីមូលហេតុចម្បងមួយដែលធ្វើឱ្យសហគមន៍មិនអាចផលិតសូត្របានច្រើន ដើម្បីសមស្របទៅនឹងតម្រូវការក្នុងសហគមន៍ថា៖ «ចិត្តខ្ញុំចង់ថាពង្រីកមុខរបរនេះ មិនចង់ឱ្យទៅទិញ ពីប្រទេសជិតខាងនោះទេ។ អ៊ីចឹង! បរិវេនដីយើងតូច យើងមិនអាចផលិតជាសូត្រឱ្យបានច្រើនទេ ដូច្នេះទាមទារឱ្យមានដីធំ ដាំមនបានច្រើន ពូជចាប់ពី៣ទៅ៥លានកូន ដែលទាមទារឱ្យមានការដាំដើមមន ២ទៅ៣ហិចតា តែសព្វថ្ងៃដាំបានតែ ១ហិចតាទេ»។

លោក រិន ណារ៉ាន់ បន្តថា ការបាញ់ថ្នាំគីមី លើចម្ការ ក៏ជាបញ្ហាចម្បងធ្វើឱ្យដង្កូវនាងងាប់។ បញ្ហាផ្សេងទៀតគឺខ្វះខាតវត្ថុធាតុដើម សម្រាប់យកមកត្បាញ ជាហូល ផាមួង ក្រម៉ានេះ មិនមែនតែជាបញ្ហាសម្រាប់លោកតែម្នាក់នោះទេ តែសម្រាប់ការផលិតសូត្រនៅកម្ពុជាផងដែរ។

បណ្ឌិត ម៉ី កល្យាណ ប្រធានក្រុមប្រឹក្សាភិបាលនៃសកលវិទ្យាល័យ ភូមិន្ទភ្នំពេញ លើកឡើងថា ប្រទេសកម្ពុជា នាំចូលសរសៃសូត្រ ពីបរទេសចំនួន ៤០០ តោន ក្នុង១ឆ្នាំ។ ការនាំចូលទាំងនេះ ធ្វើឱ្យយើងខាតថវិការជាតិ ប្រមាណ២៥ ទៅ៣០លានដុល្លា រួមទាំងបាត់ឱកាសការងារ និងផលិតផលក្នុងស្រុក។

បញ្ហាប្រឈមក្នុងការខាតបង់ទាំងនេះ និងការបង្កើនការផលិតឡើងវិញនូវសរសៃសូត្រក្នុងស្រុក លោកបណ្ឌិត និងមន្ត្រីមួយចំនួន ក្នុងសកលវិទ្យាល័យ នាំគ្នាបង្កើតក្រុមការងារ ឈ្មោះថា ខ្សែសង្វាក់ផលិតកម្មសូត្រ។ ក្រុមការងារខាងលើ បានចាប់ផ្តើមពីការស្រាវជ្រាវពូជដង្កូវនាង កាលពីឆ្នាំ២០១៧។

លោកបណ្ឌិត ម៉ី កល្យាណ បាននិយាយថា៖ «យើងចាប់ផ្តើមពីការចិញ្ចឹមដង្កូវនាង មានសកលវិទ្យាល័យភូមិន្ទភ្នំពេញបានរៀបចំបង្កើតដើម្បីធ្វើការស្រាវជ្រាវ និងឱ្យសហការីនៅតាមបណ្តាខេត្តនីមួយៗចាប់ផ្តើមធ្វើការបន្ត»។

នៅក្នុងមហោស្រព សិល្បៈជាតិតម្បាញសូត្រ កាលពីពេលកន្លងទៅនេះ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ លោកស្រី ភឿង សកុណា បានអះអាងថា ផ្អែកតាមឯកសារកាទូតចិន ពលរដ្ឋខ្មែរចេះត្បាញសូត្រ មានក្បាច់ផ្កាភ្ញី មានភាពភ្លឺរលោង រួមទាំងតម្លៃខ្ពស់ក្នុងសតវត្សទី១៣។

លោកស្រី រដ្ឋមន្ត្រីបានបន្តទៀតថា រាជរដ្ឋាភិបាល បានបន្តការលើកទឹកចិត្តការដាំដើមមន ចិញ្ចឹមដង្កូវនាង និងបង្កើនការផលិតក្នុងស្រុក សម្រាប់ផ្គត់ផ្គង់ផលិតកម្មសូត្រ និងការកាត់បន្ថយការនាំចូលសរសៃសូត្រពីបរទេស។

លោកបណ្ឌិត ម៉ី កល្យាណ លើកឡើងបញ្ជាក់បន្ថែមថា ប្រសិនបើកម្ពុជាអាចដាំដើមមន ចិញ្ចឹមដង្កូវនាងឡើងវិញ នោះកម្ពុជាមិនខាតបង់ថវិការនោះទេ និងអាចផ្តល់ឱកាសការងារជាពិសេសស្ត្រី។ លោកលើកឡើងថា៖ «ភាគច្រើនស្រីៗគឺគាត់មិនត្រូវចំណាកស្រុកទៀតនោះទេ ការងារនេះជាការងារស្រាលៗ អាចអង្គុយជុំគ្នាពី ១០ទៅ២០នាក់។ ទាំងនេះជាការងារសម្រាប់ផ្តល់ជូនពួកគាត់ផង ចំណូលផង មានរឿងចំណេញច្រើនណាស់។ សូត្រនេះមិនជាប់ទាក់ទងនឹងបរិស្ថានអ្វីច្រើននោះទេ កាន់តែបង្កើនឱ្យបរិស្ថានល្អ ដោយការដាំមន និងសំខាន់នោះគឺកំណើនសេដ្ឋកិច្ច និងទេសចរណ៍ផងដែរ»។

ទោះបីជា យើងមានមណ្ឌលស្រាវជ្រាវ និងក្រុមការងារជំនាញផ្នែកសរសៃសូត្រនេះ ក៏យើងនៅតែជួបឧបសគ្គច្រើន។ បណ្ឌិតខាងលើ ជឿថាយើងអាចកាត់បន្ថយការនាំចូលសូត្រនៅចន្លោះ ៥ទៅ១០ឆ្នាំខាងមុខ៕

## ជំនួយ៣១០លាន ដុល្លារអាមេរិកត្រូវ បានផ្ដល់ជូនកម្ពុជា

*ដោយ ៖ ផល សុផានិត*

ជំនួយអភិវឌ្ឍន៍ផ្លូវការជប៉ុន ដែលមានទឹកប្រាក់សរុប៣៤.១៣៨ លានយ៉េន ឬប្រមាណ៣១០ លានដុល្លារអាមេរិក ត្រូវបានចុះហត្ថលេខាលើលិខិតប្តូរសារស្តីពីការផ្តល់ជំនួយនេះ ក្រោមអធិបតីភាពរបស់នាយករដ្ឋមន្ត្រីកម្ពុជា សម្តេចតេជោ ហ៊ុន សែន នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០។

រាជរដ្ឋាភិបាលជប៉ុនបានផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការជប៉ុន ដែលមានទឹកប្រាក់សរុប ៣៤.១៣៨ លានយ៉េន (ប្រមាណ៣១០លានដុល្លារអាមេរិក) ដល់រាជរដ្ឋាភិបាលកម្ពុជា លើការអនុវត្តគម្រោងហិរញ្ញប្បទានឥតសំណងចំនួន ៣ គម្រោង និងឥណទានសម្បទានចំនួន២គម្រោង។

ហិរញ្ញប្បទានឥតសំណងសម្រាប់អនុវត្តមាន ទី១ គម្រោងការពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ក្នុងក្រុងតាខ្មៅ ដែលមានទឹកប្រាក់ចំនួន ៣.៤២១លានយ៉េន (ប្រមាណ៣១លានដុល្លារអាមេរិក) ទី២ គម្រោងសមាហរណកម្មការបោសសម្អាតមីន និងសង្គ្រោះជនពិការដោយសារមីន ដែលមានទឹកប្រាក់ចំនួន ១.០០០លានយ៉េន (ប្រមាណ ៩លានដុល្លារអាមេរិក) និងទី៣ គម្រោងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ដែលមានទឹកប្រាក់ចំនួន ៣០០លានយ៉េន (ប្រមាណ២,៧ លានដុល្លារអាមេរិក)។

ចំពោះឥណទានសម្បទានសម្រាប់អនុវត្តទៅលើ២គម្រោងដែលមាន ទី១ គម្រោងធ្វើឱ្យប្រសើរនូវផ្លូវជាតិលេខ៥ ដំណាក់កាលទី២ (ថ្លាម្អម-បាត់ដំបង និងសិរីសោភ័ណ្ឌ-ប៉ោយប៉ែត) ដែលមានទឹកប្រាក់ ១៧.៧០២ លានយ៉េន (ប្រមាណ ១៦១លានដុល្លារអាមេរិក) និង ទី២ គម្រោងធ្វើឱ្យប្រសើរនូវផ្លូវជាតិលេខ៥ ដំណាក់កាលទី៣(ព្រែកក្តាម-ថ្លាម្អម) ដែលមានទឹកប្រាក់ ១១.៧១៥លានយ៉េន(ប្រមាណ១០៦,៥ លានដុល្លារអាមេរិក)។

ហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទាន ដែលផ្តល់ដោយរដ្ឋាភិបាលជប៉ុននេះ នឹងជួយលើកកម្ពស់បន្ថែមទៀត នូវការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម នៃព្រះរាជាណាចក្រកម្ពុជា ហើយព្រមទាំងពង្រឹងទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការ រវាងប្រជាជាតិទាំងពីរ ផងដែរ៕




*ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន (ស្តាំ) រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកឧត្តម Sugano Yuichi ប្រធានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)ក្នុងពិធីចុះហត្ថលេខាលើលិខិតប្តូរសារស្តីពីការផ្តល់ជំនួយ។ **រូបភាព៖ ហ្វេសប៊ុកនាយករដ្ឋមន្ត្រី***

# អាជ្ញាធរ៖ ពលរដ្ឋត្រូវប្រុងប្រយ័ត្ន និងការពារសុខភាពពីបញ្ហាអាកាសធាតុ

**ខេត្តមួយចំនួនអាចនឹងរងផលប៉ះពាល់ដោយបាតុភូតធម្មជាតិខ្យល់កន្ត្រាក់ និងផ្គររន្ទះ បូកផ្សំនឹងតំបន់ខ្លះបែរជាជួបនឹងការឡើងកំដៅខ្ពស់រហូតដល់ជាង៨០អង្សារសេ សម្រាប់ឆ្នាំ២០២០នេះ។**



ក្រុមការងារមន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រះសីហនុ បានដឹកទឹកចែកជូនប្រជាពលរដ្ឋ នៅក្នុងឃុំវាលរេញ។ **រូបភាព៖ ក្រសួងធនធានទឹក និងឧត្តុនិយម**

*ដោយ៖ អមរិន្ទ ដានុត*

ខេត្តមួយចំនួនអាចនឹងរងផលប៉ះពាល់ដោយបាតុភូតធម្មជាតិខ្យល់កន្ត្រាក់ និងផ្គររន្ទះ បូកផ្សំនឹងតំបន់ខ្លះបែរជាជួបនឹងការឡើងកំដៅខ្ពស់រហូតដល់ជាង៤០អង្សារសេ សម្រាប់ឆ្នាំ២០២០នេះ។

ក្រសួងធនធានទឹក និងឧត្តុនិយមបានប្រកាស និងអំពាវនាវឱ្យប្រជាពលរដ្ឋ បង្កើនការប្រុងប្រយ័ត្នចំពោះបាតុភូតធម្មជាតិទាំងបាតុភូតរន្ទះ ខ្យល់កន្ត្រាក់ និងការឡើងកំដៅ ដែលអាចនឹងកើតមានតែលើខេត្តមួយចំនួន ដូចជា ខេត្តសៀមរាប បាត់ដំបង ឧត្តរមានជ័យ បន្ទាយមានជ័យ និងខេត្តប៉ៃលិនជាដើម។

យោងតាមសេចក្តីជូនដំណឹងរបស់ក្រសួងធនធានទឹក ចេញកាលពីថ្ងៃទី១០ ខែមីនា ស្តីពីស្ថានភាពធាតុអាកាសនៅកម្ពុជាថា ចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០បង្ហាញថា កម្រិតសម្ពាធទាបនៅលើផ្ទៃដី និងសម្ពាធខ្ពស់នៅរយៈកម្ពស់ គ្របដណ្តប់មកលើប្រទេសកម្ពុជា ដែលស្ថានភាពបែបនេះ ធ្វើឱ្យធាតុអាកាសកើនក្តៅនៅពេលថ្ងៃ។

ក្រសួងបានបញ្ជាក់បន្ថែមទៀត បណ្តាខេត្តនៅតំបន់វាលទំនាបកណ្តាលនឹងមានសីតុណ្ហភាពអប្បបរមាពី២៦-២៨អង្សាសេ ខណៈសីតុណ្ហភាពអតិបរមាពី៣៧-៣៩អង្សាសេ ប៉ុន្តែផ្នែកខ្លះ អាចមានភ្លៀងធ្លាក់ពីខ្សោយទៅមធ្យម។

ចំពោះបណ្តាខេត្តនៅតំបន់ខ្ពង់រាប ព្រៃសាន សីតុណ្ហភាពអប្បបរមា ពី២៦-២៨អង្សាសេ និងសីតុណ្ហភាពអតិបរមា ពី៣៤-៣៦អង្សាសេ។ ចំណែកបណ្តាខេត្តនៅតំបន់មាត់សមុទ្រមានសីតុណ្ហភាពអប្បបរមា ពី២៦-២៨អង្សាសេ និងសីតុណ្ហភាពអតិបរមា ពី៣៥-៣៧អង្សាសេ ដែលក្នុងកំឡុងពេលនោះអាចមានភ្លៀងធ្លាក់ខ្សោយផងដែរ។

ជាមួយគ្នានេះ ក្រសួងក៏អំពាវនាវដល់ប្រជាពលរដ្ឋ សូមប្រុងប្រយ័ត្ន នូវបាតុភូតផ្គររន្ទះ និងខ្យល់កន្ត្រាក់ និងត្រូវថែរក្សាសុខភាពក្នុងពេលអាកាសធាតុក្តៅនាពេលថ្ងៃ។

> “ទោះបីថាមានភ្លៀងកក់ខែ ប៉ុន្តែអាកាសធាតុបានកើនកំដៅឡើងដល់៤០អង្សាសេ ទៅដល់៤១អង្សាសេ។ វាអាចក្តៅខ្លាំង និងអាចអូសបន្លាយដល់ខែឧសភា។ ... សីតុណ្ហភាពឆ្នាំនេះក្តៅជាងឆ្នាំមុនបន្តិច ប៉ុន្តែមានភ្លៀងកក់ខែច្រើនជាងឆ្នាំមុន ដែលទាមទារឱ្យប្រជាពលរដ្ឋត្រូវមានការប្រុងប្រយ័ត្នខ្ពស់ផងដែរ។”



*លោក ចាន់ យុត្ថា អ្នកនាំពាក្យក្រសួងធនធានទឹក និងឧតុនិយម។* ***រូបភាព៖ សហការី***

អ្នកនាំពាក្យក្រសួងធនធានទឹក និងឧតុនិយម លោក ចាន់ យុត្ថា បានឱ្យដឹងថា បច្ចុប្បន្ននេះ ស្ថានភាពអាកាសធាតុ មានការកើនឡើងនូវកម្តៅជាបន្តបន្ទាប់ ដែលតំបន់ខ្លះអាចមានពី៣៨ ទៅ៣៩អង្សារសេ និងតំបន់ខ្លះអាចហក់ទៅដល់ ៤០ទៅ៤២អង្សាសេ ដែលចាំបាច់ប្រជាពលរដ្ឋត្រូវបង្កើនការប្រុងប្រយ័ត្ន និងថែរក្សាសុខភាពជាចាំបាច់។

លោកបន្តថា ទោះបីថាមានភ្លៀងកក់ខែ ប៉ុន្តែអាកាសធាតុបានកើនកំដៅឡើងដល់៤០អង្សាសេ ទៅដល់៤១អង្សាសេ។ វាអាចក្តៅខ្លាំង និងអាចអូសបន្លាយដល់ខែឧសភា។

អ្នកនាំពាក្យរូបនេះបន្ថែមថា សីតុណ្ហភាពអតិបរមាអាចបន្តកើនឡើង ដោយក្នុងរដូវបុណ្យចូលឆ្នាំខ្មែរនាខែក្រោយនេះ អាចឡើងដល់ ៤១ ទៅ៤២អង្សាសេ។

លោក ចាន់ យុត្ថា បានថ្លែងឱ្យដឹងដែរថា៖ «សីតុណ្ហភាពឆ្នាំនេះក្តៅជាងឆ្នាំមុនបន្តិច ប៉ុន្តែមានភ្លៀងកក់ខែច្រើនជាងឆ្នាំមុន ដែលទាមទារឱ្យប្រជាពលរដ្ឋត្រូវមានការប្រុងប្រយ័ត្នខ្ពស់ផងដែរ»។

លោកស្រី ឱ វណ្ណឌីន អ្នកនាំពាក្យក្រសួងសុខាភិបាល បានមានប្រសាសន៍ថា អាកាសធាតុក្តៅអាចបង្កផលប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋ បើសិនពុំមានការប្រុងប្រយ័ត្ន។ នៅពេលអាកាសធាតុក្តៅ ញើសនឹងចេញច្រើន ដែលអាចធ្វើឱ្យរាងកាយឆាប់បាត់បង់ជាតិទឹក។ ដូចនេះ បើមិនមានការពិសារទឹកឱ្យបានគ្រប់គ្រាន់ទេ វាអាចនឹងប៉ះពាល់ដល់សុខភាព។

លោកស្រីថ្លែងថា៖ «សរីរាង្គមនុស្សយើង ត្រូវការទឹកយ៉ាងតិច១លីត្រកន្លះទៅ២លីត្រក្នុងមួយថ្ងៃ ហើយមនុស្សយើងមិនត្រូវស្ថិតនៅក្រោមកំដៅថ្ងៃយូរពេកទេ បើកាលណានៅផ្ទាល់យូរពេលថ្ងៃក្តៅខ្លាំង វាអាចធ្វើឱ្យរលាកស្បែក រមាស់ ឡើងដំបៅ និងហប់ ដង្ហក់ ដែលអាចឈានដល់ការដួលសន្លប់»។

អ្នកនាំពាក្យរូបនេះបានបន្តថា នៅពេលអាកាសធាតុក្តៅខ្លាំង ត្រូវមានការប្រុងប្រយ័ត្នលើជំងឺផ្សេងៗដូចជា រាគរូស ការពុលចំណីអាហារជាដើម។

ក្រសួងសុខាភិបាលតែងតែធ្វើការណែនាំនូវវិធានការការពារខ្លួនក្នុងអំឡុងពេលអាកាសធាតុក្តៅខ្លាំងត្រូវជៀសវាងស្ថិតនៅក្រោមកម្តៅថ្ងៃយូរពេក ត្រូវស្លៀកសម្លៀកបំពាក់វែងៗដើម្បីការពារកម្តៅថ្ងៃ ទទួលទានទឹកឱ្យបានច្រើន និងទទួលទានអាហារឱ្យបានគ្រប់គ្រាន់ ឆ្អិនល្អ និងរក្សាអនាម័យជាប្រចាំ។

វេជ្ជបណ្ឌិត ឯកទេស ជំងឺទូទៅ សើរស្បែកសន្លាក់ នៃមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត លោក ប្រាក់ ណារុំ បានប្រាប់ឱ្យដឹងថា អាកាសធាតុក្តៅខ្លាំងធ្វើឱ្យខ្សោះជាតិទឹកក្នុងខ្លួនមនុស្សយើង ដូច្នេះ អាចរងគ្រោះបើសិនជាយើងមិនបានព្យាបាលឱ្យទាន់ពេលវេលាទេនោះ។



*លោកស្រី ឱ វណ្ណឌីន អ្នកនាំពាក្យក្រសួងសុខាភិបាល។* ***រូបភាព៖ សហការី***





*ខ្យល់កន្ត្រាក់មកលើ ០៣ឃុំ (សរសស្គម្ភ, ល្វា, ត្រីញ័រ) ស្រុកពួក ខេត្តសៀមរាប ធ្វើឱ្យប៉ះពាល់ផ្ទះប្រជាពលរដ្ឋរបើកដំបូលចំនួន ៣១ខ្នង និងរលំចំនួន ០២ខ្នង។* ***រូបភាព៖ សហការី***

លោកបន្តថា៖ «ប្រសិនបើយើងមិនញ៉ាំទឹកគ្រប់គ្រាន់ទេនោះ វានឹងអាចប៉ះពាល់ខូចខាតដល់សរីរាង្គក្នុងខ្លួនយើងដូចជា បេះដូង ខួរក្បាល តម្រងនោមជាដើម។ ដោយឡែក ជនដែលប្រឈមខ្លាំង គឺកុមារអាយុក្រោម៥ឆ្នាំ និងមនុស្សចាស់អាយុលើសពី៨៥ឆ្នាំ»។

លោកវេជ្ជបណ្ឌិត ប្រាក់ ណារុំ បានផ្តល់ជាដំបូន្មានថា ដើម្បីទប់ស្កាត់ និងការពារពីជំងឺផ្សេងៗក្នុងអាកាសធាតុក្តៅនេះ ដំណោះស្រាយល្អបំផុតគឺទទួលទានទឹកឱ្យបានច្រើន យ៉ាងហោចណាស់៦កែវក្នុងមួយថ្ងៃ ប្រសិនបើកូនក្មេងអាចតិចជាងនេះ និងស្ត្រីដែលមានផ្ទៃពោះត្រូវទទួលទានទឹកឱ្យបានញឹកញាប់បំផុតតាមដែលអាចធ្វើទៅបាន។

លោកវេជ្ជបណ្ឌិត បានប្រាប់បន្តថា៖ «ក្រៅពីទទួលទានទឹក យើងអាចទទួលទានផ្លែឈើជំនួសបានដូចជា ឪឡឹក ទឹកដូង និងដើម្បីបង្ការគ្រោះថ្នាក់ផ្សេងៗ ពេលចេញទៅក្រៅ គួរពាក់មួក ដែលមានកំបាំង ឬហាមធំត្រូវមានបាំងឆ័ត្រនៅជាប់នឹងខ្លួន គួរកុំស្លៀកសម្លៀកបំពាក់ណាដែលតឹងពេក គួរតែប្រើសម្លៀកបំពាក់ណាដែលមានពណ៌ស្រាលៗ»។

អ្នកស្រី ព្រុំ រឿន វ័យ៥២ កសិករក្នុងស្រុកព្រះស្តេច ខេត្តព្រៃវែងបាននិយាយពីការបារម្ភរបស់អ្នកស្រីចំពោះសុខភាពចៅតូចៗរបស់គាត់ ពិសេសពេលធ្វើដំណើរក្រោមកំដៅថ្ងៃទៅសាលារៀន។

អ្នកស្រីថា សុខភាពសំខាន់ ការសិក្សាក៏សំខាន់ ដូចនេះអ្នកស្រីមិនអាចហាមចៅៗបានទេ ណាមួយ ឪពុកម្តាយរបស់ពួកគេ ក៏មិនបានធ្វេសប្រហែសនឹងសុខភាពរបស់ពួកគេដែរ។

អ្នកស្រី ព្រុំ រឿន បានថ្លែងថា៖ «អាកាសធាតុប្រែជាក្តៅខុសពីខែមុនៗ និងហាក់ដូចជាក្តៅខ្លាំងជាងឆ្នាំមុនទៅទៀត។ វាពិតជាពិបាកក្នុងការរស់នៅ ទាំងមនុស្ស និងសត្វ ពិសេសការធ្វើដំណាំមិនសូវបានផល ដោយសារយើងមិនសូវមានទឹកគ្រប់គ្រាន់ យើងទុកទឹកប្រើប្រាស់សម្រាប់ខែក្តៅ»។

រាជរដ្ឋាភិបាលកម្ពុជាធ្លាប់បានចេញនូវសារាចរណែនាំមួយកាលពីខែវិច្ឆិកាកន្លងទៅ ដោយឱ្យក្រសួង ពាក់ព័ន្ធ និងអាជ្ញាធរត្រូវចាត់វិធានការថែរក្សាទឹកទុកនៅរដូវប្រាំងឆ្នាំនេះ ដោយសារប្រទេសកម្ពុជា អាចនឹងជួបប្រទះនូវធាតុអាកាសក្តៅខ្លាំង ដោយសាររដូវវស្សាមកដល់យឺតយ៉ាវ ទឹកភ្លៀងតិចតួច។ជាមួយគ្នានោះដែរ រដ្ឋាភិបាលក៏បានណែនាំដល់ប្រជាពលរដ្ឋបង្កបង្កើនស្រូវប្រាំងតែមួយដងក្នុងឆ្នាំនេះ និងរក្សាទឹកទុកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃក្នុងគ្រួសារ៕



*ក្រុមការងារមន្ទីរធនធានទឹក ខេត្តព្រះសីហនុ បានដឹកទឹកចែកជូនប្រជាពលរដ្ឋ នៅក្នុងឃុំវាលរេញ។* ***រូបភាព៖ ក្រសួងធនធានទឹក***



*ខ្យល់កន្ត្រាក់បានបំផ្លាញផ្ទះប្រជាពលរដ្ឋ។* ***រូបភាព៖ សហការី***

# ពលរដ្ឋទូទៅអាចដឹងដោយខ្លួនឯង ថាមានមេរោគកូវីដ១៩ ឬអត់ បាន

*ដោយ ៖ អមរិន្ទ ដានុត*

គ្រូពេទ្យជនជាតិជប៉ុនម្នាក់បានផ្តល់ដំបូន្មានដ៏ល្អក្នុងការបង្ការវីរុសថ្មី កូដវីដ១៩ ដោយលោកបានពន្យល់ថា មេរោគកូវីដ១៩នេះអាចនឹងមិនបញ្ចេញរោគសញ្ញាក្នុងពេល១៤ទៅ១៧ថ្ងៃទេ ប៉ុន្តែពលរដ្ឋធម្មតាអាចពិនិត្យសុខភាពរបស់ខ្លួនឯងបាន។

តើត្រូវធ្វើដូម្តេចទើបបុគ្គលម្នាក់ៗអាចដឹងថាពួកគាត់បានឆ្លង ឬមិនបានឆ្លង? បើសិនជារង់ចាំដល់បុគ្គលនោះក្តៅខ្លួន ឬ/និងក្អកទើបទៅកាន់មន្ទីរពេទ្យ អ្នកជំងឺអាចនឹងមានភាគរយឆ្លងដល់៥០ភាគរយទៅហើយ។ អ្នកជំនាញបានផ្តល់នូវវិធីពិនិត្យដោយខ្លួនឯងដែលគ្រប់គ្នាអាចធ្វើបាន ដោយនៅរៀងរាល់ព្រឹក អ្នកត្រូវដកដង្ហើមឱ្យវែង ហើយទប់ដង្ហើមរបស់អ្នកឱ្យបានលើស១០វិនាទី ហើយប្រសិនបើអ្នកអាចធ្វើបានដោយមិនក្អក មិនពិបាក មិនមានភាពថប់ក្នុងដើមទ្រូង នោះបង្ហាញថាអ្នកមិនបានឆ្លងមេរោគនេះទេ។ ដូចនេះអ្នកអាចពិនិត្យដោយខ្លួនឯងបានជារៀងរាល់ព្រឹកនៅក្នុងបរិយាកាសដែលមានខ្យល់បរិសុទ្ធ។

ជាមួយគ្នានេះដែរ គ្រូពេទ្យជប៉ុនដែលព្យាបាលជំងឺវីរុសក្លូវណានេះបានផ្តល់ដំបូន្មានក្នុងការបង្ការវាដោយពិសាទឹកឱ្យបានញឹកញាប់។ អ្នកទាំងអស់គ្នាគួរតែប្រាកដថា មាត់ និងបំពង់ករគឺត្រូវមានសំណើមជានិច្ច ដែលជាហេតុអ្នកគួរតែពិសាទឹករៀងរាល់១៥នាទីម្តង។ ហេតុអ្វីបានជាត្រូវការពិសាទឹកញឹកញាប់? ដោយសារតែ ប្រសិនបើមេរោគនោះចូលក្នុងមាត់របស់អ្នក ការផឹកទឹកអាចជួយលាងមេរោគទម្លាក់តាមបំពង់អាហារ ហើយនៅពេលមេរោគធ្លាក់ដល់ក្រពះ អាស៊ីតអ៊ីដ្រូក្លរីដនៅក្នុងក្រពះអ្នកអាចនឹងសំលាប់មេរោគនេះ ប៉ុន្តែប្រសិនបើអ្នកមិនពិសាទឹកជាប្រចាំទេ មេរោគអាចចូលតាមផ្លូវខ្យល់ចូលទៅក្នុងសួតរបស់អ្នកដែលវាគ្រោះថ្នាក់សម្រាប់អ្នកបំផុត៕



*រូបភាពដំណាង។ រូបភាព៖ បរទេស*

# ឧបករណ៍តន្ត្រីបុរាណខ្មែរផ្សាភ្ជាប់នឹងជីវិតប្រជាជន

*ដោយ ៖ ផល សុផានិត*



ឧបករណ៍តន្ត្រី និងភ្លេងប្រពៃណីបុរាណខ្មែរ មានច្រើនប្រភេទ ច្រើនសណ្ឋាន និងច្រើនវង់ ដូចជាតន្ត្រីវង់ភ្លេងរបាំព្រះរាជទ្រព្យ ភ្លេងពិណពាទ្យ ភ្លេងមហោរី សម្រាប់ប្រគុំក្នុងពិធីសាសនា ប្រគុំឡើងសម្រាប់ សម្តែងរបាំផ្សេងៗ ប្រគុំក្នុងពិធីបុណ្យ និងពិធីមង្គលការជាដើម។ ពលរដ្ឋខ្មែរ ទាំងក្នុង និងក្រៅប្រទេស បានដឹង និងស្គាល់ ឧបករណ៍វង់ភ្លេងបុរាណ ប្រពៃណីខ្មែរទាំងនោះ តាមរយៈសិល្បករ សិល្បការិនីពេលប្រគុំ និងសម្តែងក្នុងពិធីនានាខាងលើ។

មានសម្បុរស្រអែមបែបខ្មែរបុរាណ វ័យប្រមាណ៦០ឆ្នាំ លោក មៀច មុយ ជាអ្នកផលិតឧបករណ៍តន្ត្រីបុរាណ និងជាសាស្ត្រាចារ្យមហាវិទ្យាល័យតូរ្យតន្ត្រី ម្នាក់ផងនោះ បានមានប្រសាសន៍នៅក្នុងពិធីសំពះគ្រូប្រចាំឆ្នាំរបស់មហាវិទ្យាល័យកាលពីពេលថ្មីៗនេះ ថា លោកចេះផលិតឧបរណ៍តន្ត្រីទាំងនេះតពីដូនតា និងបានចូលសិក្សាបន្តពីគ្រូៗខ្លះ ព្រមទាំងការអំណោយផលពីកំណើតរបស់ខ្លួនផងដែរ។

សាស្ត្រាចារ្យរូបនេះបានបញ្ជើបថា លោកបានចាប់មុខរបរជាអ្នកផលិតឧបករណ៍តន្ត្រីបុរាណនេះ អស់ពេលជាង២០ឆ្នាំមកហើយ បន្ទាប់ពីលោកបានចូលនិវត្តន៍ និងដោយសារការស្រឡាញ់មរតកវប្បធម៌ជាតិ ស្រឡាញ់នូវឧបរណ៍តន្ត្រីរបស់ជាតិខ្មែរ។

លោក មៀច មុយ បានមានប្រសាសន៍បន្ថែមថា៖ «ណឹង!ឧបករណ៍នេះជាអត្តសញ្ញាណរបស់ជាតិ ហើយមិនថាអឺរ៉ុប អាស៊ី សុទ្ធតែមានវប្បធម៌រៀងៗខ្លួន។ បរទេសមាន ហ្គីតា វីយូឡុង យើងខ្មែរមានស្គរដៃ ទ្រ តាយេ ចាប៉ី»។

បុរសសម្បុរស្រអែម ខាងលើ បានបន្តថា បច្ចុប្បន្នលោកមានសិប្បកម្មផ្ទាល់ខ្លួនមួយ ស្ថិតក្នុងស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ មានផលិតឧបរកណ៍តន្ត្រីប្រពៃណីបុរាណខ្មែរ ដូចជា ស្គរធំ ស្គរដៃ ទ្រ តាយេ ចាប៉ី ខ្លុយ ជាដើម។ សម្រាប់តម្លៃវិញនោះ មានចន្លោះចាប់ពី៥០០ដុល្លារ ទៅដល់៣០០០ដុល្លា ទៅតាមប្រភេទនៃឧបករណ៍នីមួយៗ។

សាស្ត្រាចារ្យផ្នែកតន្ត្រីបុរាណដដែលនេះ បានបន្តទៀតថា ទីផ្សារនៃឧបករណ៍តន្ត្រីបុរាណខ្មែរ បច្ចុប្បន្ននេះ មិនជាមានបញ្ហាចោទនោះទេ ដោយអតិថិជនមកជាវដល់ទីតាំងសិប្បកម្ម និងហាងចែកចាយក្នុងរាជធានីភ្នំពេញ ដោយសារពួកគេស្គាល់តៗគ្នា ព្រមទាំងមានការផ្សព្វផ្សាយតាមបណ្តាញសង្គម ដែលមិនពិបាកដូចពីមុនដែលអ្នកលក់ត្រូវដឹកទៅកាន់កន្លែងឆ្ងាយៗទេ។

លោក មៀច មុយ បានបន្តថា៖ «ខ្ញុំអរគុណណាស់ចំពោះអតិថិជនដែលបានគាំទ្រឧបករណ៍ តន្ត្រីវប្បធម៌ខ្មែរ បើមិនចូលរួមជួយថែរក្សានោះទេ វានឹងបាត់បង់នៅថ្ងៃខាងមុខណាមួយ។ បើទោះបីជាពួកគាត់មិនចេះលេងឧបករណ៍ខាងលើ ក៏ពួកគាត់យកទៅដាក់តាំងក្នុងផ្ទះសម្រាប់អោយក្មេងៗជំនាន់ក្រោយបានស្គាល់ដែរ»។

លោកបានបញ្ជាក់បន្ថែមថា ក្នុងរដូវកាលដែលឧបករណ៍ទាំងនេះមានតម្រូវការច្រើន គ្រួសាររបស់លោកអាចរកចំណូលបាន១០០០ដុល្លារក្នុង១ខែ តែថវិកាទាំងនេះក៏ត្រូវចំណាយលើសំភារៈ វត្ថុធាតុដើម និងកម្មករ។ កូនចៅជំនាន់ក្រោយរបស់លោក ចេះផលិត និងលេងឧបករណ៍តន្ត្រីបុរាណនេះ ព្រមទាំងបានបង្រៀនដល់កូនចៅខ្មែរជំនាន់ក្រោយជាច្រើននាក់ថែមទៀតផង៕





# កាន់តែធ្ងន់ក សម្រាប់បុគ្គលល្មើសនឹង ច្បាប់ចរាចរណ៍ផ្លូវគោកថ្មី

*ដោយ ៖ អមរិន្ទ ដានុត*


*អនុក្រឹត្យស្តីពីការកែសម្រួលការពិន័យអន្តរការណ៍ចំពោះអំពើរល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក។ រូបភាព៖ ស៊ីអេសស៊ី*

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា បានចេញអនុក្រឹត្យថ្មីមួយ ដោយធ្វើការកែសម្រួលនូវអនុក្រឹត្យ ស្តីពីការពិន័យអន្តរការណ៍ ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក ក្នុងនោះចំនួនទឹកប្រាក់នៃការផាកពិន័យត្រូវបានសម្រេចដំឡើងប្រាក់ពិន័យចរាចរណ៍ពី៣ ទៅ៥ដងនៃប្រាក់ពិន័យនាពេលបច្ចុប្បន្ននេះ។

យោងតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាល នៅថ្ងៃទី៩ ខែមីនា ឆ្នាំ ២០២០ បានឱ្យដឹងថា អនុក្រឹត្យថ្មីនេះបានកែប្រែនូវមាត្រាមួយចំនួនដូចជា មាត្រា៦ មាត្រា៧ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៣ មាត្រា១៤ និងមាត្រា១៥ នៅក្នុងជំពូកទី៣ ពាក់ព័ន្ធបទល្មើស និងចំនួនទឹកប្រាក់ត្រូវពិន័យ នៃអនុក្រឹត្យលេខ៤៤ ដែលចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧កន្លងមក។

រដ្ឋាភិបាលបានកែសម្រួលការពិន័យចំពោះអំពើល្មើសនឹងច្បាប់ចរាចណ៍ផ្លូវគោក ដោយពិន័យជាប្រាក់ចាប់ពី៦មុឺនរៀល រហូតដល់៤លានរៀលចំពោះអ្នកមិនគោរពច្បាប់ចរាចរណ៍ ដែលចាប់ពីអ្នកជិះម៉ូតូមិនពាក់មួកសុវត្ថិភាព ឬពាក់មិនត្រឹមត្រូវតាមស្តង់ដារជាតិ ឬពាក់ដោយមិនដាក់គន្លឹះខ្សែសុវត្ថិភាព។ ដោយមិនគោរពភ្លើងសញ្ញា (ភ្លើងស្តុប) និងសញ្ញាចរាចរណ៍ និងការប្រើប្រាស់ទូរសព្ទក្នុងពេលបើកបរទាំងអ្នកជិះឡាន និងម៉ូតូ បើកបរប្រើសញ្ញាសូរសព្ទមិនត្រឹមត្រូវតាមប្បញ្ញត្តិច្បាប់ បើកបរបង្ហោះ រេចុះឡើង ឆាប ឬគៀរ រហូតដល់ការបើកបរក្រោមភាពស្រវឹងជាដើម។

អនុក្រឹត្យនេះបានបន្តទៀតថា សម្រាប់ម្ចាស់ហាងលក់យានយន្តគ្រប់ប្រភេទដែលមិនបានបំពេញបែបបទចុះបញ្ជីយានយន្ត សុំបណ្ណសម្គាល់យានយន្ត និងសុំផ្លាកលេខមុនប្រគល់ឱ្យអ្នកទិញ នឹងត្រូវពិន័យផងដែរ ចាប់ពី១សែន២មុឺនរៀល ដល់២លាន៤សែនរៀលតាមទំហំឡាន ខណៈអ្នកដែលមិនស្នើសុំលិខិតធ្វើអាជីវកម្មដឹកជញ្ជូន នឹងត្រូវពិន័យចាប់ពី១សែន៥មុឺន ដល់៣សែនរៀល។

សម្រាប់ឪពុកម្តាយ ឬអាណាព្យាបាល ក៏ត្រូវទទួលខុសត្រូវលើការប្រព្រឹត្តិល្មើសច្បាប់ចរាចរណ៍របស់កូនផងដែរ ដែលប្រព្រឹត្តដោយអនីតិជនមានអាយុចាប់ពី ១៥ឆ្នាំ ដល់ក្រោម១៨ឆ្នាំផងដែរ។

លោក គង់ រតនៈ នាយកវិទ្យាស្ថានសុវត្ថិភាពចរាចរណ៍ បានមានប្រសាសន៍ប្រាប់សារព័ត៌មានក្នុងស្រុក វីអូឌីថា ការដំឡើងប្រាក់ពិន័យ គឺគ្រាន់តែជាផ្នែកមួយនៃការដោះស្រាយបញ្ហាចរាចរណ៍នៅកម្ពុជាប៉ុណ្ណោះ តែលោកថា បញ្ហាសំខាន់នោះគឺការអនុវត្តច្បាប់ចរាចរណ៍ឱ្យមានប្រសិទ្ធភាពទៅវិញទេ។

លោកគង់ រតនៈ បានថ្លែងថា៖ «ខ្ញុំមិនហ៊ានថាយ៉ាងមេចទេ ព្រោះមិនឃើញជាក់ស្តែង តែកន្លងមក យើងឃើញថា ការដាក់ពិន័យត្រឹម១មុឺន៥ពាន់ហ្នឹង អ្នកដែលខុស គាត់សុខចិត្តបង់១មុឺនឱ្យទៅប៉ូលិស ហើយគាត់សល់បាន៥ពាន់។ សម្រាប់ខ្ញុំ គឺនៅលើសមត្ថកិច្ចខ្លួនឯង បើចង់ឱ្យឥរិយាបថរបស់អ្នកបើកបរគាត់កែប្រែ សូមឱ្យគាត់ធ្វើប្រកបដោយតម្លាភាពទៅ។ តែបើគាត់ថាគាត់ធ្វើដើម្បីតែក្រពះគាត់ ដើម្បីភាពមានបានរបស់គាត់ បើទោះបីថ្នាក់លើខិតខំយ៉ាងណាក៏ដោយ បើសិនជាអត់មានបានត្រួតពិនិត្យឱ្យច្បាស់លាស់ទៅលើទង្វើរបស់មន្ត្រីមួយចំនួនទេ យើងនឹងគ្មានប្រសិទ្ធភាពខាងអនុវត្តន៍ច្បាប់ទេ»។ ប៉ុន្តែលោក ហ៊ឹម យ៉ាន អគ្គស្នងការរងនគរបាលជាតិទទួលបន្ទុកផែនចរាចរណ៍ បានលើកឡើងការពារថា នឹងគ្មានទេអំពើពុករលួយក្នុងការអនុវត្តនេះ ដោយថា រដ្ឋបានផ្តល់ការលើកទឹកចិត្តច្រើនដល់នគរបាលចរាចរណ៍ជាមួយគ្នានិងការតាមដានផងដែរ។

អនុក្រឹត្យដដែលនេះបានបញ្ជាក់ផងដែរថា ចំពោះបុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់មន្ត្រីមានសមត្ថកិច្ច អាចមានសិទ្ធិប្តឹងតវ៉ារយៈពេល១៥ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ គិតពីថ្ងៃទទួលបង្កាន់ដៃពិន័យអន្តរការណ៍ ទៅប្រធានអង្គភាពដែលគ្រប់គ្រងលើមន្ត្រីអនុវត្តផ្ទាល់ ហើយប្រធានអង្គភាពត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ គិតពីថ្ងៃទទួលបណ្តឹង។ ចំពោះបុគ្គលណាដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ប្រធានអង្គភាពខាងលើ មានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីនៃច្បាប់។

យោងតាមរបាយការណ៍របស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ដែលបានចេញកាលពីចុងខែមករាឆ្នាំ២០២០បានឱ្យបង្ហាញថា គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក នៅទូទាំងប្រទេស នៅឆ្នាំ២០១៩ បានកើតឡើងចំនួន ៤,១២១លើក សម្លាប់មនុស្សចំនួន ១,៩៨១នាក់ និងរបួសធ្ងន់ស្រាលចំនួន ៦,១៤១នាក់។

របាយការណ៍ដដែលបានបញ្ជាក់ថា ចំនួនគ្រោះថ្នាក់នេះបានកើនឡើង ៨៤៥លើក ស្មើនឹង ២៦ភាគរយ អ្នកស្លាប់កើន ២២០នាក់ ស្មើនឹង ១២ភាគរយ និងអ្នករងរបួសកើន ១៣៧១នាក់ ស្មើនឹង ២៩ភាគរយ បើប្រៀបធៀបនឹងឆ្នាំ ២០១៨។ ករណីកើតឡើងច្រើនជាងគេ នៅក្នុងរាជធានីភ្នំពេញ ខេត្តកណ្តាល ព្រះសីហនុ និងខេត្តកំពង់ស្ពឺ ហើយមូលហេតុធំជាងគេដែលបណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍ច្រើនជាងគេ រួមមាន ការបើកបរលើសល្បឿនកំណត់ បើកបរមិនគោរពសិទ្ធិ មិនប្រកាន់ស្តាំ វ៉ាជែង ស្រវឹងកត្តាយានយន្ត និងងងុយដេក ជាដើម ហើយចំណោមអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍នៅឆ្នាំ ២០១៩ ភាគច្រើន ជាអ្នកធ្វើដំណើរតាមម៉ូតូ៕

## មនុស្សស្លាប់ និងរបួសដោយអគ្គិភ័យ

*ដោយ៖ អគ្គស្នងការដ្ឋាននគរបាលជាតិ*

ភ្នំពេញ៖ មនុស្សម្នាក់បានស្លាប់ និង៥នាក់ទៀតបានរងរបួសធ្ងន់ស្រាលក្នុងហេតុការណ៍អគ្គិភ័យ ថ្ងៃពុធ ទី២៥ ខែមីនា ឆ្នាំ២០២០ ស្ថិតនៅតាមបណ្តោយផ្លូវលេខ២២១ សង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

មន្ត្រីនគរបាលផ្នែកអគ្គិភ័យបានឱ្យដឹងថា ម្ចាស់រងគ្រោះឈ្មោះ យន ស្រ៊ីប ភេទស្រី អាយុ៧១ឆ្នាំ មុខរបរនៅផ្ទះ ហើយមូលហេតុនៃការឆាបឆេះនេះដោយសារតែ ធ្លាក់ដបសាំងឆាបឡើងបង្កជាអគ្គិភ័យកើតឡើង។

ប្រភពដដែលបន្តថា ក្នុងហេតុការណ៍ខាងលើបានឆេះផ្ទះលេខ ៣៥A ផ្នែកខាងក្រោមព្រមទាំងសម្ភារប្រើប្រាស់និងប្រកបអាជីវកម្មអស់ទាំងស្រុង និងម៉ូតូចំនួន៣គ្រឿង ហើយបានបណ្តាលឱ្យរាលដាល ដល់ផ្ទះអ្នកជិតខាងចំនួន៤ផ្ទះជាប់គ្នា។

អគ្គិភ័យនេះបានបណ្តាលឱ្យស្លាប់មនុស្សម្នាក់ឈ្មោះ យន ស្រ៊ីប ភេទស្រី អាយុ៧១ឆ្នាំ និងមនុស្ស៥នាក់ទៀតរងរបួសធ្ងន់ស្រាល។ ក្នុងប្រតិបត្តិការខាងលើសមត្ថកិច្ចបានប្រើប្រាស់រថយន្តពន្លត់អគ្គិភ័យចំនួន១២គ្រឿង ប្រើប្រាស់ទឹកអស់៦ឡាន៕

## ផ្ទុះគំរបស៊ីទែនស្តុកប្រេងឥន្ធនៈ របួសមនុស្ស៣នាក់

*ដោយ ៖ អគ្គស្នងការដ្ឋាននគរបាលជាតិ*

មនុស្ស៣នាក់ បានរងរបួសក្នុងហេតុការណ៍ផ្ទុះគំរបស៊ីទែនស្តុកប្រេងឥន្ធនៈក្រោមដីមួយក្នុងស្ថានីយ៍មួយកន្លែង បង្កជាអណ្តាតភ្លើងកាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០២០ នៅក្នុងភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

តាមរបាយការណ៍របស់ លោកវរសេនីយ៍ឯក ប៊ុន ផេង ស្នងការរងខេត្តបានឱ្យដឹងថា អ្នករងរបួសចំនួន៣នាក់ ត្រូវបានជួយសង្គ្រោះ និងយកទៅមន្ទីរពេទ្យ ដែលពួកគេជាឪពុក កូនប្រុសារ និងចៅប្រុស។

លោកស្នងការរង បានបញ្ជាក់ថា តាមការសាកសួរជុំវិញករណីផ្ទុះគំរបស៊ីទែននេះ នៅមុនពេលកើតហេតុនោះកូនប្រុសារ និងចៅរបស់ជនរងគ្រោះ បានបូមប្រេងពីឡានដឹកប្រេងដាក់ក្នុងស៊ីទែនស្តុបប្រេង ពេលដែលកំពុងបូមស្រាប់តែព្នុសម្លេងផ្ទុះចេញពីម្ខាងរបងហើយខ្ទាតផ្កាភ្លើង ឆាបក្លាយជាអណ្តាតភ្លើង និងបណ្តាលឱ្យផ្ទុះស៊ីទែនប្រេងក្រោមដីដែលកំពុងបញ្ចូលប្រេង ភ្លាមនោះកូនប្រុសារដែលជាជនរងគ្រោះដែរនោះ បានរត់ទៅបិតក្បាលរ៉ូប៊ីណេប្រេងដើម្បីកុំឱ្យឆាបឆេះកាន់តែខ្លាំង និងប្រើបំពង់ឧស្ម័នបាញ់ពន្លត់បាញ់ រហូតរងរបួសខ្លួនឯងធ្ងន់ធ្ងរ ត្រូវបានបញ្ជូនទៅព្យាបាលនៅគ្លីនិកឯកជន តែដោយអាការៈរបួសធ្ងន់ធ្ងរក៏បន្តបញ្ជូនទៅមន្ទីរពេទ្យបង្អែកមិត្តភាពកម្ពុជា ជប៉ុន នៅស្រុកមង្គលបូរី។

ក្នុងហេតុការណ៍គ្រោះអគ្គីភ័យនេះ ត្រូវបានបាញ់ទឹកពន្លត់អស់១រថយន្តទើបគ្រប់គ្រងស្ថានការណ៍នោះបានមិនបង្ករាលដាលទៅផ្ទះអ្នកជិតខាង។ ចំពោះមូលហេតុបង្កឱ្យមានការផ្ទុះគំរបស៊ីទែនស្តុកប្រេងនេះគឺបណ្តាលមកពីការធ្វេសប្រហែសរបស់ម្ចាស់ស្ថានីយ៍ ដែលគ្រប់គ្រងប្រេងស្តុកនោះខ្វះលក្ខណៈបច្ចេកទេស៕

# សម្តេចប៉ាបធ្វើពិធីប្រទានពរ និងពិធីលើកលែងទោសឱ្យរួចពីបាបជាពិសេស




*សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានធ្វើពិធីអធិដ្ឋាន ប្រទានពរពិសេសពីទីក្រុងរ៉ូម។ **រូបភាព៖ បរទេស***

*ដោយ៖ កែវ កញ្ញា*

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានធ្វើពិធីអធិដ្ឋាន ប្រទានពរពិសេស និងពិធីលើកលែងទោសឱ្យរួចពីបាបដល់អ្នកដែលនឹងចូលរួមមើល ស្តាប់ការប្រទានពរ «urbi et orbi» ដែលមានន័យថា សម្រាប់ទីក្រុងរ៉ូមទៅកាន់ពិភពលោកទាំងមូល។ ពិធីនេះ ធ្វើនៅថ្ងៃទី២៧ ខែមីនា នៅម៉ោង៦ល្ងាច កន្លងទៅ ម៉ោងនៅទីក្រុងរ៉ូម គឺម៉ោងប្រមាណ១២ យប់ថ្ងៃដដែលនៅក្នុងប្រទេសកម្ពុជា។

ពិធីប្រទានពរពិសេស និងពិធីលើកលែងទោសឱ្យរួចពីបាបនេះ ធ្វើឡើងសម្រាប់អ្នកជំងឺឆ្លងមេរោគកូវីដ១៩ អ្នកស្លាប់ដោយសារជំងឺនេះ អ្នកកំពុងមើលថែរក្សាពួកគេ មិត្តភក្តិ និងក្រុមគ្រួសារដែលកំពុងអធិដ្ឋានរួមគ្នាដើម្បីអ្នកជំងឺទាំងនោះ។

លោក អូលីវីយេ ឆ្មឹតអឺស្ល៊ែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានពន្យល់នៅថ្ងៃបន្ទាប់តាមការផ្សាយផ្ទាល់ពីកម្ពុជា ដោយមានការផ្សាយឡើងវិញអំពីព្រឹត្តិការណ៍ដែលសម្តេចប៉ាបបានរៀបចំនៅទីក្រុងរ៉ូម។

លោក អភិបាលបានមានប្រសាសន៍ថា សម្តេចប៉ាបបានអធិដ្ឋានមិនមែនសម្រាប់តែទីក្រុងរ៉ូមនោះទេ គឺសម្រាប់ពិភពលោកទាំងមូល ដែលរួមទាំងប្រទេសកម្ពុជាផងដែរ។ លោកអភិបាលបានលើកឡើងអំពីព្រះគម្ពីរដែលសម្តេចប៉ាបបានយកមករិះគិតនៅក្នុងថ្ងៃដដែលនោះ ស្តីអំពីព្រះយេស៊ូធ្វើឱ្យរលកស្ងប់(មក៤,៣៥-៤១) ដែលទាក់ទងទៅនឹងជំនឿលើព្រះយេស៊ូពិតប្រាកដ និងការផ្ញើជីវិតទៅព្រះបិតាឯស្ថានបរមសុខ។

លោកអភិបាលបញ្ជាក់ថា៖ «តាមពិតព្រះជាម្ចាស់កំពុងធ្វើដំណើរជាមួយយើង និងណែនាំឱ្យយើងភ្ញាក់ស្មារតីដែរ អំពីការរស់នៅប្រចាំថ្ងៃ អំពីរបៀបដែលយើងមានទម្លាប់អំពីប៉ុន្មានឆ្នាំកន្លងមកនៅក្នុងជីវិតរបស់យើង ការរៀបចំកាលវិភាគ ការរៀបចំការងារ ការរៀបចំអ្វីៗទាំងអស់ដែលប្រហែលជួនកាលយើងភ្លេចអ្នកក្រីក្រដែរ អ្នកតូចតាចដែរ»។

លោកអភិបាលបន្ថែមថា ដូច្នេះនៅពេលនេះជាពេលវេលាមួយដែលយើងត្រូវសហការគ្នាដើម្បីឱ្យពិភពលោកទាំងមូលភ្ញាក់ស្មារតី យល់ថាយើងជាក្រុមគ្រួសារតែមួយ។ ប្រទេសនីមួយៗមានប៉ុន្មានរយនាក់ដែលទទួលមរណភាពពីមួយថ្ងៃទៅមួយថ្ងៃ។ សម្តេចប៉ាបបានជម្រុញយើងបង្កើតភាតរភាព ការលើកទឹកចិត្តគ្នា ការធ្វើដំណើរជាមួយគ្នា ដើម្បីប្រឆាំងនិងឈ្នះនឹងកូវីដ ១៩ និងបន្តដោយទូលអង្វរព្រះយេស៊ូ ឱ្យរំដោះយើង ឱ្យព្រះយេស៊ូលើកលែងទោសឱ្យយើង ឱ្យយើងមានសេចក្តីសង្ឃឹម មានជំនឿរឹងមាំ ដើម្បីតស៊ូ និងដើម្បីប្រឆាំងនឹងកូវីដ១៩។



នៅក្នុងវីដេអូ យើងបានឃើញ សម្តេចប៉ាបបានថ្វាយបង្គំនៅមុខរូបសំណាកព្រះនាងម៉ារី និងរូបសំណាកឈើឆ្កាងដែលមកពីព្រះវិហារសន្តម៉ាកស្សែល។ ឈើឆ្កាងនេះជាឈើឆ្កាងល្បីល្បាញមួយ សម្រាប់ប្រជាជននៅទីក្រុងរ៉ូម ហើយត្រូវបានប្រសិទ្ធនាមថា «ឈើឆ្កាងដែលបានសង្គ្រោះ ប្រជាជននៅទីក្រុងរ៉ូម»។ នៅឆ្នាំ១៥២២ គ្រានោះមានមេរោគប៉េស (Plague)ដែលបានសម្លាប់ជនជាតិរ៉ូមយ៉ាងច្រើន។ ព្រះសហគមន៍បានយកឈើឆ្កាងនេះហែជុំវិញទីក្រុងរ៉ូមរយៈពេល១៦ថ្ងៃ ហើយប្រជាជនបានជាសះស្បើយ។

លោកអភិបាលបន្ថែមថា៖ «ឈើឆ្កាងនេះជាឈើឆ្កាងពិសេស ដែលយើងមើលឃើញព្រះភក្ត្ររបស់ព្រះយេស៊ូរងទុក្ខលំបាកយ៉ាងខ្លាំង ណែនាំឱ្យព្រះយេស៊ូប្រមូលទុក្ខលំបាករបស់យើងផ្ញើទៅព្រះបិតា។ ហើយសម្តេចប៉ាបបានប្រមូលទុក្ខលំបាក ការស្រែករបស់យើង ការពិបាករបស់យើង អ្នកដែលស្លាប់ពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីផ្ញើថ្វាយទៅព្រះជាម្ចាស់។ ក្រោយមកសម្តេចប៉ាបបានអធិដ្ឋាននៅមុខព្រះកាយព្រះគ្រីស្ត ឱ្យព្រះគ្រីស្តគង់នៅជាមួយយើង ការពារយើង ថែរក្សាយើង ឱ្យយើងទទួលជីវិត»។

តាមការពន្យល់របស់លោកអភិបាល អំពីព្រះពរពិសេសដែលសម្តេចប៉ាបបានធ្វើគឺ «urbi et orbi» ដែលពោរពេញដោយការលើកលែងទោសពេញលក្ខណៈ (Plenary Indulgency) ដែលមានន័យថា «សម្រាប់បងប្អូនដែលកំពុងស្លាប់ដោយកូវីដ១៩ កាលពីយប់មិញ ឱ្យគេបានទទួលការលើកលែងទោស ដើម្បីធ្វើដំណើរជាមួយព្រះជាម្ចាស់ទៅស្ថានបរមសុខ»។

អ្នកជំងឺ និងអ្នកមើលថែជំងឺ អាចរួបរួមគ្នាក្នុងវិញ្ញាណផងដែរ នៅពេលណាយើងចូលរួមតាមរយៈប្រព័ន្ធផ្សព្វផ្សាយ អនឡាញ ដើម្បីចូលរួមអភិបូជា ឬការសូត្រផ្គាំ ឬដើរឈើឆ្កាង ឬក៏ពិធីស្នឹងស្មាធនានា។ នេះបើតាមការបញ្ជាក់របស់ លោកកាឌីណាល់ម៉ូរ៉ូ ពីយ៉ាសែនសា (Mauro Piacenza) ប្រធាននាយកដ្ឋានគុណធម៌ និងភាពអនុគ្រោះ រួមនិង សន្តអាសនៈនៃព្រះសហគមន៍កាតូលិក ក្នុងក្រឹត្យពិសេសមួយកាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០នេះ ទាក់ទងនឹងស្ថានភាពបច្ចុប្បន្នមានជំងឺកូវីដ១៩ កំពុងរីករាលដាលជាសកល។

លោកកាឌីណាល់ម៉ូរ៉ូ ថ្លែងថា ចូលព្រះវិហារដើម្បីអធិដ្ឋាន ថ្វាយបង្គំព្រះអង្គតាមរយៈព្រះកាយព្រះគ្រីស្ត ឬក៏អានស្នឹងស្មាធិ៍ព្រះគម្ពីរឱ្យបានកន្លះម៉ោងរាល់ថ្ងៃ ឬក៏សូត្រផ្គាំជាមួយព្រះនាងម៉ារី ឬក៏អធិដ្ឋានដើរផ្លូវឈើឆ្កាង ឬក៏សូត្រផ្គាំនៃព្រះហឫទ័យមេត្តាករុណា។ ការអធិដ្ឋានទាំងអស់នោះជាសម្រែកលាន់ទៅដល់ព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពខ្ពង់ខ្ពស់បំផុត សូមទូលអង្វរព្រះអង្គទប់ស្កាត់ការរីករាលដាលនាពេលបច្ចុប្បន្ននេះ នាំឱ្យអស់អ្នកដែលកំពុងតែរងទុក្ខដោយសារតែការរីករាលដាលនេះបានធូរស្បើយ និងសូមទូលអង្វរព្រះអង្គផ្តល់ឱ្យអស់អ្នកដែលទទួល មរណភាពមានជីវិតអស់កល្បជានិច្ច។

នាយកដ្ឋានគុណធម៌ និងភាពអនុគ្រោះនៃព្រះសហគមន៍កាតូលិកសូមបញ្ជាក់ថា គេអាចទទួលការលើកលែងទោសដ៏ពេញលេញនោះបាន លុះត្រាតែចៀសវាងអំពើបាប បានរួមចិត្តនឹងលោកបូជាចារ្យដែលថ្វាយអភិបូជានៅព្រះវិហារ និងបានអធិដ្ឋានតាមផ្ទះរៀងៗខ្លួន សូត្រផ្គាំជាមួយព្រះនាងម៉ារី អធិដ្ឋានដើរផ្លូវឈើឆ្កាង សូត្រធម៌«ឱព្រះបិតាយើងខ្ញុំ» និងធម៌«បពិត្រព្រះនាងម៉ារី» ឬក៏បានអធិដ្ឋានតាមរបៀបផ្សេងៗទៀត តាមរយៈការផ្សាយផ្ទាល់លើប្រព័ន្ធផ្សព្វផ្សាយនានាក្នុងពេលតែមួយ។

ការអធិដ្ឋានទាំងអស់នោះ គួរតែថ្វាយទៅព្រះអង្គដោយមានចិត្តមេត្តាចំពោះអស់អ្នកជឿដែលរងទុក្ខ ហើយដោយចិត្តសង្ឃឹម ជឿទុកចិត្តលើព្រះជាម្ចាស់។ ម្យ៉ាងទៀត គ្រីស្តបរិស័ទត្រូវតែមានឆន្ទៈចង់បំពេញសកម្មភាពតាមលក្ខខណ្ឌធម្មតា គឺ«ចង់ទទួលអគ្គសញ្ញាលើកលែងទោស ចង់ទទួលព្រះកាយព្រះគ្រីស្ត និងចង់អធិដ្ឋានតាមចេតនារបស់សម្តេចប៉ាប»។

ក្នុងលិខិតដដែលនោះ ក៏បានបញ្ជាក់ដែរថា «ចំពោះអ្នកដែលហៀបនឹងស្លាប់ ដោយគ្មានអគ្គសញ្ញាលាបប្រេង ហើយបានត្រៀមខ្លួន មានទំលាប់នឹងការអធិដ្ឋានជាលំដាប់នៅក្នុងជីវិត នោះព្រះសហគមន៍ក៏ផ្តល់ឱ្យពួកគាត់អាចទទួលការលើកលែងទោសដ៏ពេញលេញនោះបាន ទោះបីជាស្ថានភាពបច្ចុប្បន្នមិនឱ្យពួកគាត់អាចបំពេញសកម្មភាពតាមលក្ខខណ្ឌធម្មតាទាំងបីនោះក៏ដោយ។ ក៏ប៉ុន្តែ ព្រះសហគមន៍សូមផ្តល់អនុសាសន៍ចំពោះបងប្អូនទាំងនោះឱ្យយករូបឈើឆ្កាងជាប់នឹងដៃ សំលឹងមើលទៅលើព្រះអង្គដែលត្រូវគេឆ្កាង»៕





# សិក្ខាសាលាស្តីអំពីបរិយាបន្នសង្គម សម្រាប់ជនងាយរងគ្រោះ




វិទ្យាស្ថានសន្តប៉ូលបានរៀបចំសិក្ខាសាលាស្រាវជ្រាវ ស្តីអំពី "បរិយាបន្នសង្គមនៃប្រទេសកម្ពុជា" ដើម្បីបញ្ជ្រាបដល់និស្សិតមកពីស្ថាប័នចំនួន៣ដែលមានចំនួនប្រមាណជា ១៥០ នាក់ ឱ្យយល់ដឹងពីបរិយាបន្នសង្គមដោយគ្មានការរើសអើង។ សិក្ខាសាលានេះរៀបចំឡើងដោយមានការសហការជាមួយនឹងអង្គការការីតាសកម្ពុជា និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលប្រព្រឹត្តទៅនៅថ្ងៃទី ១១ និង ១២ មីនា ២០២០ នៅវិទ្យាស្ថានសន្តប៉ូល ក្នុងស្រុកត្រាំកក់ខេត្តតាកែវ។

នៅក្នុងកិច្ចចាប់ផ្តើមនៃអង្គសិក្ខាសាលាលោក ផុន សុផល នាយកវិទ្យាស្ថាន សន្តប៉ូល ក៏បានមានប្រសាសន៍នៅក្នុងកិច្ចស្វាគមន៍ថា នេះជាសិក្ខាសាលាស្រាវជ្រាវកម្រិតឧត្តមសិក្សាលើកទី១ ដែលមានតំណាងមកពីអង្គការក្រៅរដ្ឋាភិបាលចូលរួម។ លោកក៏បានបង្ហាញផងដែរអំពីគោលបំណងនៃសិក្ខាសាលានេះគឺធ្វើឡើងដើម្បីឱ្យនិស្សិតមកពីគ្រឹះស្ថានអប់រំនៅកម្រិតឧត្តមសិក្សា និងស្ថាប័នអង្គការមួយចំនួននៅក្នុងប្រទេសកម្ពុជា សិក្សាស៊ីជម្រៅនិងរកគំនិតរួមក្នុងការអភិវឌ្ឍបរិយាបន្នសង្គមក្នុងប្រទេសកម្ពុជា។

លោកនាយកបន្ថែមថា យើងចង់ឱ្យពួកគាត់រិះគិត ពិភាក្សាអំពី «តើគោលនយោបាយអភិវឌ្ឍបរិយាបន្នទៅ ក្នុងប្រទេសកម្ពុជា តើវាមានការពាក់ព័ន្ធនៅក្នុងស្ថាប័ន ឬក្រសួងនៅក្នុងប្រទេសកម្ពុជាកម្រិតណា និងមានការអនុវត្តដល់កម្រិតណា?»។

អង្គសិក្ខាសាលាមានការចូលរួមពីនិស្សិតមកពី វិទ្យាស្ថានសន្តប៉ូល វិទ្យាស្ថានជាតិសង្គមកិច្ច និងសកលវិទ្យាល័យភូមិន្ទភ្នំពេញ ហើយមានកិច្ចពិភាក្សាជាក្រុមតូចៗ ដោយផ្តោតទៅលើវិស័យក៏ដូចជាស្ថាប័ន៥ ដូចជា វិស័យអប់រំ សាសនា ស្ថាប័នរដ្ឋ ស្ថាប័នឯកជន និងអង្គការក្រៅរាជរដ្ឋាភិបាល។

លោកសុផល បានបញ្ជាក់ថា ក្រោយពេលបញ្ចប់សិក្ខាសាលានេះ វិទ្យាស្ថាននឹងចេញជាសេចក្តីថ្លែងការណ៍រួមមួយ សម្រាប់វិស័យទាំង៥ខាងលើ។

លោក គឹម រតនា នាយកប្រតិបត្តិនៃអង្គការការីតាសកម្ពុជា និងជាដៃគូសហការណ៍របស់វិទ្យាស្ថានសន្តប៉ូលក្នុងសិក្ខាសាលានេះផងដែរ បានមានប្រសាសន៍ថា ក្នុងរយៈពេល២ថ្ងៃមកនេះ យើងឃើញថា កិច្ចពិភាក្សាមានការផុសផុលយ៉ាងខ្លាំងក្នុងចំណោមអ្នកចូលរួម ហើយយើងមើលឃើញថា មានកង្វះខាត ឧបសគ្គបន្ថែមទៀត ដើម្បីធ្វើយ៉ាងណាសម្របសម្រួល ដើម្បីអប់រំផ្សព្វផ្សាយ ដើម្បីធ្វើយ៉ាងណា ជនដែលមានពិការភាពចូល ជនដែលងាយរងគ្រោះហ្នឹង គាត់ទទួលបានសេវាកម្មទាំងអស់ហ្នឹង គាត់ទទួលបាននូវគោលនយោបាន គាត់បានយល់ច្បាស់ យ៉ាងពេញលក្ខណៈ ហើយចូលរួមយ៉ាងពេញលេញ»។

ចំណែកយុវតី ប៊ុនណា រ៉ាទី មកពីវិទ្យាស្ថានជាតិសង្គមកិច្ច ផ្នែកសង្គមវិទ្យាបានឱ្យដឹងថា៖ «ការលើកស្ទួយបរិយាបន្នសង្គមក្នុងប្រទេសកម្ពុជា គឺមានសារៈសំខាន់ខ្លាំង ដើម្បីជួយពន្លឿនកិច្ចការមួយចំនួននៅក្នុងសង្គម ដើម្បីឱ្យសង្គមមានការអភិវឌ្ឍទៅមុនទៀត ក៏ដូចលើកស្ទួយបងៗមានពិការភាព ឱ្យពួកគាត់ខិតខំបញ្ចេញនូវសមត្ថភាព»។

«នៅក្នុងការអភិវឌ្ឍសង្គម ដើម្បីឱ្យមានតម្លាភាពចាំបាច់ត្រូវតែមានបរិយាបន្នសង្គម» នេះជាសម្តីរបស់និស្សិតឈ្មោះណាន សុខា មកពីសកលវិទ្យាល័យភូមិន្ទភ្នំពេញ។ សុខា បន្ថែមថា លោកនឹងចូលរួមចែករំលែកទៅកាន់មិត្តភក្តិរួមថ្នាក់ និងរួមការងារ ដើម្បី ឱ្យគេស្គាល់និងយល់អំពីការធ្វើបរិយាបន្នក្នុងសង្គម។

លោកមូ សម្រេច ជាជនមានពិការភាពបានឡើងមកចែកចាយបទពិសោធជីវិតដល់សិក្ខាកាមទាំងអស់។ លោកមានប្រសាសន៍ថា ដោយការដាក់បញ្ចូលជនមានពិការភាពឱ្យចូលរួមក្នុងសង្គម ទើបលោកអាចមានវត្តមាននៅក្នុងថ្ងៃសិក្ខាសាលានេះ។ សម្រេចបានបញ្ចប់ការសិក្សាផ្នែកសង្គមសាស្ត្រនៅវិទ្យាស្ថានសន្តប៉ូល ហើយសព្វថ្ងៃលោកកំពុងបម្រើការងារនៅមណ្ឌលសុខសាន្តរបស់ព្រះសហគមន៍កាតូលិក ជាកន្លែងមួយទទួលកុមារមានពិការភាពឱ្យអាចបន្តការសិក្សា។

លោក សម្រេចបានសំណូមពរដល់ស្ថាប័ននៅក្នុងសង្គមកម្ពុជាជួយលើកកម្ពស់ និងបន្ថែមការអប់រំពិសេសដល់ជនមានពិការភាពដែលបានបន្តការសិក្សារហូតដល់ឧត្តមសិក្សា ដើម្បីឱ្យពួកគាត់អាចមានសមត្ថភាពបម្រើការងារដូចជារូបលោក៕

# យុវជនកាតូលិកភូមិភាគភ្នំពេញ ឈ្វេងយល់ពីយុវជន និងភាពក្រីក្រ

*ដោយ៖ កាតូលិកភ្នំពេញ*

យុវជនកាតូលិកជាង៥០រូប មកពីមណ្ឌលសកម្មភាពទាំង៦ នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានចូលរួមសិក្ខាសាលាក្រោមប្រធានបទ «យុវជន និងភាពក្រីក្រ» នាដើមខែមីនា ដែលដឹកនាំដោយការិយាល័យយុវជនជំទង់ កុមារ និងគ្រួសារនៅព្រះវិហារសន្តសិលាពោធិ៍ធំ មណ្ឌលសកម្មភាពភ្នំពេញខាងជើង។

លោកស៊ាន់ សារឿន ប្រធានការិយាល័យយុវជន ជំទង់ កុមារ និងគ្រួសារ បានឱ្យដឹងថា សិក្ខាសាលានេះផ្តោតទៅលើ «យុវជន និងភាពក្រីក្រ» ដែលបានបញ្ជ្រាបតាមរយៈការអប់រំ ទ្រព្យសម្បត្តិ និងសុខភាព។

លោកបញ្ជាក់ថា ប្រធានបទនេះសំខាន់ ព្រោះយុវជនត្រូវទទួលការអប់រំ ត្រូវមានចំណេះដឹងស្គាល់ពីស្ថានភាពព្រះសហគមន៍ និងសង្គមដែលកំពុងតែរស់នៅ ក៏ដូចជាចំណេះដឹងផ្សេងៗដែលគេត្រូវតែមាន ព្រោះនេះជាការយល់ដឹងមួយជួយឱ្យគេមានលក្ខណៈគ្រប់គ្រាន់ក្នុងការអភិវឌ្ឍខ្លួនទៅថ្ងៃអនាគត។

លោបានថ្លែងថា៖ «ខ្ញុំសង្ឃឹមថា តាមរយៈសិក្ខាសាលារយៈពេលពីរថ្ងៃមកនេះ អ្នកចូលរួមនឹងទទួលបានចំណេះដឹង និងបទពិសោធកាន់តែច្បាស់ថែមទៀតនូវអ្វីដែលគេគួរ និងមិនគួរធ្វើនិងអ្វីដែលជាអាទិភាពនៅក្នុងជីវិត។ ត្រូវចេះរៀបចំចិត្តគំនិតនឹងការរស់នៅសមស្របជាសាវ័ករបស់ព្រះយេស៊ូដែលជាគំរូនៅក្នុងការប្រកាសដំណឹងល្អ»។

កញ្ញា លី ទៀង ជាយុវជននៃព្រះវិហារសន្តសិលា ពោធិ៍ធំ បានបញ្ជាក់ថា កញ្ញាពេញចិត្តចំពោះប្រធានបទនេះ ព្រោះការអប់រំមានសារៈសំខាន់នៅក្នុងការរស់នៅដោយចេះអធ្យាស្រ័យយោគយល់គ្នាទៅវិញទៅមកដោយមានគុណធម៌សច្ចធម៌នៅក្នុងខ្លួន។




*យុវជនកាតូលិកជាង៥០រូបចូលរួមក្នុងសិក្ខាសាលា។*

ជារៀងរាល់ឆ្នាំ ការិយាល័យយុវជន ជំទង់ កុមារ និងគ្រួសារ តែងតែរៀបចំសិក្ខាសាលា ដើម្បីជួយដល់យុវជន យុវនារីនៅក្នុងការរិះគិតទាំងជីវិតនៅក្នុងព្រះសហគមន៍ និងសង្គមនៅតាមព្រះសហគមន៍នានាក្នុងភូមិភាគភ្នំពេញ។

ដោយឡែកឆ្នាំនេះការិយាល័យត្រូវបានបែងចែកអង្គសិក្ខាសាលាជាពីរផ្នែក គឺយុវជន យុវនារី ដែលមកឈ្វេងយល់រយៈពេលពីរថ្ងៃខាងលើទាំងនេះមកពីមណ្ឌលសកម្មភាពភ្នំពេញខាងជើង ភ្នំពេញខាងត្បូង ភ្នំពេញថ្មី បាសាក់ មេគង្គ និងតាខ្មៅនិងមួយក្រុមទៀតគឺយុវជននៃមណ្ឌលសកម្មភាពតាកែវ កំពត និងព្រះសីហនុនឹងធ្វើរគ្នានាពេលឆាប់ៗខាងមុខនេះ៕

# សម្តេចប៉ាបផ្ញើសារទៅកាន់ទិវាអធិដ្ឋានពិភពលោកសម្រាប់ការត្រាស់ហៅ

*ដោយ៖ កាតូលិកភ្នំពេញ*

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានផ្ញើសារទៅកាន់ពិភពលោកក្នុងទិវាពិភពលោកនៃការអធិដ្ឋានសម្រាប់ការត្រាស់ហៅដែលនឹងរៀបចំឡើងនៅក្នុងថ្ងៃទី ០៣ ខែឧសភាខាងមុខនេះ។




សាររបស់សម្តេចប៉ាប ដើម្បីអបអរសាទរទិវាពិភពលោកលើកទី ៥៧ នៃការអធិស្ឋានសម្រាប់ការត្រាស់ហៅនេះ បានរំលឹកឡើងវិញនូវលិខិតមួយដែលសម្តេចបានសរសេរកាលពីឆ្នាំមុន ដែលសម្តេចបានជ្រើសរើសពាក្យបួនយ៉ាងគឺ «ការដឹងគុណ ការលើកទឹកចិត្ត ក្លាហាន អស់សង្ឃឹម និងការឆ្លើយប»។

សម្តេចប៉ាបមានប្រសាសន៍ថា ពាក្យដំបូងនៃការត្រាស់ហៅ គឺការដឹងគុណ។ សម្តេចប៉ាបបន្តថា គ្រប់ការត្រាស់ហៅទាំងអស់ កើតឡើងដោយសារសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់។ «យើងនឹងទទួលជោគជ័យ នៅក្នុងការស្វែងរក និងទទួលបានការត្រាស់ហៅម្តង ដោយការបើកចិត្តនៅក្នុងឧបការគុណ និងការសម្រេចរបស់ព្រះជាម្ចាស់» សម្តេចប៉ាបបញ្ជាក់បន្ថែម។

សម្តេចប៉ាបបានបន្ថែមទៀតថា ជាទូទៅខ្មោចបានបន្លាចយើង ហើយរារាំងផ្លូវរបស់យើង។ នៅពេលដែលយើងត្រូវបានត្រាស់ហៅ ឱ្យស្ថិតក្នុងទីសុវត្ថិភាព ដូចជារៀបការ បួសជាបូជាចារ្យ ជាបព្វជិត-ជីតា។ ការសម្តែងចេញដំបូងរបស់យើងគឺច្រើន តែគ្មានទំនុកចិត្ត ហើយតែងនិយាយថា ប្រកដហើយ ការត្រាស់ហៅនេះមិនមែនសម្រាប់ខ្ញុំទេ! ឬ តើនេះអាចជាផ្លូវត្រឹមត្រូវទេ? តើព្រះអម្ចាស់ចង់ឱ្យខ្ញុំធ្វើកិច្ចការងារនេះឬ?

សម្តេចប៉ាបបន្តថា ព្រះអម្ចាស់ជ្រាបថាជំរើសសំខាន់ៗសម្រាប់ជីវិតនោះ គឺការត្រាស់ហៅដោយសេចក្តីក្លាហាន។ ព្រះអង្គជ្រាបនូវការសង្ស័យដែលយើងបានជួប ហើយព្រះអង្គមានបន្ទូលថា «ចូរតាំងចិត្តក្លាហានឡើង ខ្ញុំទេតើ កុំខ្លាចអី!»។ នៅក្នុងជំនឿ យើងដឹងថា ព្រះអង្គគង់នៅជាមួយយើង ហើយមករកយើងរាល់ពេល មិនដែលបំភ្លេចយើងឡើយ។ ឃ្លាខាងលើនេះ បានធ្វើឱ្យយើងរួចផុតពីការធ្លាក់ទឹកចិត្តដែលរារាំងយើងមិនឱ្យទទួលបានភាពរីករាយក្នុងការត្រាស់ហៅរបស់យើង។

លោកបន្ថែមថា ការត្រាស់ហៅរបស់ព្រះជាម្ចាស់គឺឱ្យយើងបម្រើដំណឹងល្អ ដូចជាសន្តសិលាបានមានប្រសាសន៍ថា បំណងប្រាថ្នា និងភាពរីករាយរបស់យើងរួមរស់ជាមួយបរាជ័យ និងការភ័យខ្លាចរបស់យើង។ សម្តេចប៉ាបសង្កត់ធ្ងន់ថា ទោះជាយ៉ាងណាព្រះយេស៊ូគង់នៅក្បែរយើងជានិច្ច។

នៅក្នុងសារនេះ សម្តេចប៉ាបបានសំណូមពរទៅកាន់ព្រះសហគមន៍ក្នុងទិសដៅលើកកម្ពស់ការត្រាស់ហៅរបស់ព្រះជាម្ចាស់ ដោយមានប្រសាសន៍ថា៖ «សូមឱ្យព្រះសហគមន៍អាចប៉ះដួងចិត្តរបស់គ្រីស្តបរិស័ទ និងឱ្យពួកគាត់ម្នាក់ៗរកឃើញឧបការគុណនៃការត្រាស់ហៅរបស់ព្រះជាម្ចាស់ក្នុងជីវិត និងរកឃើញសេចក្តីក្លាហានដើម្បីឆ្លើយចាសឬបាទ ទៅកាន់ព្រះជាម្ចាស់ ហើយចេះតស៊ូដោយមានជំនឿលើព្រះយេស៊ូ បន្ទាប់មកឱ្យឆាកជីវិតរបស់ពួកគេក្លាយជាចម្រៀងសរសើរតម្កើងសម្រាប់ព្រះជាម្ចាស់ សម្រាប់បងប្អូនឯទៀតៗ និងសម្រាប់ពិភពលោកទាំងមូល»៕

## សម្តេចប៉ាបអធិដ្ឋានទូលអង្វរព្រះជាម្ចាស់បញ្ចប់ជម្ងឺ

*ដោយ៖ កាតូលិកភ្នំពេញ*

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានអធិដ្ឋានសូមទូលអង្វរដល់ព្រះជាម្ចាស់ សូមឱ្យបញ្ចប់នូវការឆ្លងរីករាលដាលនៃជំងឺ ជាពិសេស គឺការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ ដែលកំពុងតែផ្ទុះខ្លាំងនៅអឺរ៉ុប។

វ៉ាទីកង់ញូវ (VATICAN News) បានរាយការណ៍ថា ការអធិដ្ឋាននេះបានធ្វើឡើងនៅក្នុងអំឡុងពេលដែលសម្តេចប៉ាប បានចាកចេញពីវ៉ាទីកង់ទៅទស្សនកិច្ចនៅកន្លែងដើរធម្មយាត្រា ចំនួន ២កន្លែងនៅក្នុងទីក្រុងរ៉ូម។ នៅក្នុងអំឡុងពេលនោះ សម្តេចប៉ាបក៏បានអធិដ្ឋានសូមឱ្យទីក្រុងរ៉ូម និងពិភពលោក យកជ័យជំនះលើការរីករាលដាលនៃការផ្ទុះឆ្លងជំងឺកូវីដ១៩នេះ។ កន្លែងដែលសម្តេចប៉ាបបានអធិដ្ឋាននេះ គឺទីមួយ នៅទីលានបាស៊ីលីការនៃសន្តម៉ារី ម៉ាជ័រ និង មួយកន្លែងទៀត គឺនៅមុខឈើឆ្កាងដែលការពារទីក្រុងរ៉ូមពីគ្រោះកំណាចដែលបានកើតមានឡើងនៅអឺរ៉ុប កាលពីសតវត្សរ៍ទី១៥ និង ១៦។

សម្តេចប៉ាប បានអធិដ្ឋាននៅចន្លោះពីម៉ោង ៤ រសៀលរហូតដល់ម៉ោង ៥ កន្លះរសៀល ដោយ បានអធិដ្ឋានជាពិសេសសម្រាប់បុគ្គលិកសុខាភិបាលទាំងអស់ ព្រមទាំងអ្នកជំងឺ ឱ្យតស៊ូទប់ទល់នឹងមេរោគនេះ។ កន្លែងដែលសម្តេច ប៉ាបបានអធិដ្ឋាននេះ គឺសុទ្ធតែជាកន្លែងប្រវត្តិសាស្ត្រ និងជាកន្លែងពិសិដ្ឋ សម្រាប់អធិដ្ឋានដ៏ស័ក្តិសិទ្ធ៕

## សម្តេចប៉ាបបរិច្ចាគប្រាក់ជួយជនរងគ្រោះ

*ដោយ៖ កាតូលិកភ្នំពេញ*

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានបរិច្ចាគទឹកប្រាក់ ១០ ម៉ឺនអឺរ៉ូដល់អង្គការការីតាសអ៊ីតាលីក្នុងកាយវិការលើកទឹកចិត្តដល់អ្នកដែលរងគ្រោះដោយការឆ្លងជំងឺកូវីដ១៩ ក្នុងប្រទេសអ៊ីតាលី។ នេះបើយោងតាមសេចក្តីរាយការណ៍របស់វ៉ាទីកង់ញូវ (VATICAN News)។



ប្រទេសអ៊ីតាលី នៅតែបន្តជាប្រទេសដែលមានចំនួនករណីឆ្លងជំងឺកូវីដ-១៩ ខ្ពស់នៅអឺរ៉ុប។ រដ្ឋាភិបាលអ៊ីតាលី បានរឹតបន្តឹងបន្ថែមទៀត ដោយបញ្ជាឱ្យបិទហាងទាំងអស់ លើកលែងតែឱសថស្ថាន និងហាងលក់អាហារ។

នៅក្នុងបរិយាកាសនៃការព្រួយបារម្ភកាន់តែខ្លាំងនេះ សម្តេចប៉ាប បានបញ្ជូនវិភាគទានចំនួន ១០០.០០០ អឺរ៉ូ ទៅអង្គការការីតាសអ៊ីតាលី។ សម្តេចប៉ាបបានធ្វើការបរិច្ចាគ ដើម្បីលើកកម្ពស់សាមគ្គីភាពជាមួយអ្នកដែលងាយរងគ្រោះបំផុត។ អំណោយនេះ មិនច្រើនទេ តែជាការបង្ហាញពីភាពស្និទ្ធស្នាលខាងវិញ្ញាណ និងការលើកទឹកចិត្តរបស់សម្តេចប៉ាប ចំពោះមនុស្សដែលទទួលរងពីការរីករាលដាលនៃជំងឺនេះ និងចំពោះអ្នកដែលយកចិត្តទុកដាក់ចំពោះពួកគេ ។

ថវិកានេះមានគោលបំណងជួយដល់អង្គការការីតាសអ៊ីតាលី ក្នុងការផ្តល់នូវសេវាកម្មចាំបាច់ដើម្បីជួយដល់ជនក្រីក្រ និងងាយរងគ្រោះបំផុតនៅក្នុងសង្គម៕





# យុវនារី ម៉ារីណា ថ្វាយពាក្យសច្ចាលើកដំបូងក្នុងក្រុមដូនជីសម្ងាត់នៅកម្ពុជា

*ដោយ៖ លី សុវណ្ណា*

«ការរស់នៅដោយធ្វើការរៀងរាល់ថ្ងៃ ហាក់ដូចជាខ្វះនូវសេចក្តីស្រឡាញ់ ទោះបីខ្ញុំមានការងារល្អ និងប្រាក់ចំណូលខ្ពស់ក៏ដោយ។ (ខ្ញុំ)ចង់ទទួលបានសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ច្រើនជាង និងចង់ស្រឡាញ់ព្រះជាម្ចាស់កាន់តែច្រើនជាងផងដែរ។ ហេតុនេះរូបខ្ញុំសម្រេចចិត្តចង់ចូលបួស»។ នេះជាការរៀបរាប់របស់ ម៉ារីណា យុវនារីជាតិកូរ៉េ ដែលបានថ្វាយពាក្យសច្ចាលើកដំបូងរបស់ខ្លួន ក្នុងក្រុមដូនជីកាតូលិកសម្ងាត់នៅកម្ពុជា (ក្រុមដូនជីកាមែល) កាលពីថ្ងៃទី៨ ខែមីនា ឆ្នាំ២០២០។



*យុវនារីជាតិកូរ៉េ ម៉ារីណា ដែលបានថ្វាយពាក្យសច្ចាលើកដំបូង។ រូបភាព៖ ស៊ីអេសស៊ី*



*យុវនារីជាតិកូរ៉េ ម៉ារីណា ដែលបានថ្វាយពាក្យសច្ចាលើកដំបូង។ រូបភាព៖ ស៊ីអេសស៊ី*

ពិធីនេះប្រារព្ធក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់លោកអភិបាល អូលីវីយេ លោកអភិបាលប្រ៊ុយណូ និងអស់បូជាចារ្យ បព្វជិត បព្វជិតា គ្រីស្តបរិស័ទជាច្រើនរូបស្ថិតក្នុងអារ៉ាមបងស្រីកាមែលក្នុងស្រុកអង្គស្នួល ខេត្តកណ្តាល។

ម៉ារីណា បន្តថា រូបគាត់បានស្វែងរកក្រុមដូនជីមួយ ដែលល្អសម្រាប់ជីវិតរបស់គាត់ និងស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ដូច្នេះ គាត់មកឈ្វេងយល់នៅប្រទេសកម្ពុជា ដោយស្ម័គ្រចិត្តមកបំពេញការងារជាមួយជនមានពិការភាព នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ជនមានពិការភាពបន្ទាយព្រាប តាមរយៈក្រុមសហជីវិនព្រះយេស៊ូ។

ម៉ារីណា ជាកូនស្រីពៅ ក្នុងគ្រួសារដែលមានបងប្អូនស្រី៣នាក់ជាគ្រួសារគ្រីស្តបរិស័ទដែលមានជីវភាពល្អសមរម្យ។ ម៉ារីណា ទៀតសោតក៏មានការងារល្អ ប្រាក់ឈ្នួលខ្ពស់ផងដែរ។ ហេតុអ្វីម៉ារីណា ចង់ថ្វាយខ្លួនទៅព្រះជាម្ចាស់ ក្នុងផ្លូវជីវិតជាអ្នកបួសរស់ក្នុងអារ៉ាមសម្ងាត់បែបនេះ? ដូចម៉ារីណាបានបញ្ជាក់ គឺ ដោយសារស្រឡាញ់ព្រះជាម្ចាស់ខ្លាំង និងចង់ទទួលសេចក្តីស្រឡាញ់ពីព្រះអង្គវិញដែរ។

ទោះបីជាមានបំណងច្បាស់យ៉ាងណា ការសម្រេចចិត្តរងការរំខានពីមាតាបិតា ហើយធ្វើឱ្យពួកគាត់មិនសប្បាយចិត្តក៏ដោយ ក៏ស្ត្រីរូបនេះនៅតែតាំងចិត្តខ្ពស់មិនរាថយ។

លោក អានហូហ្សប អាឡេចសាន់ត្រា ជាឪពុកបានឱ្យដឹងថា៖ «ពេលកូនចេញពីផ្ទះ ខ្ញុំព្រួយបារម្ភ ព្រួយចិត្តពីកូន ប៉ុន្តែពេលឃើញកូនថ្វាយពាក្យសច្ចាបែបនេះមានអំណរសប្បាយវិញ និងទទួលការលួងលោមពីព្រះជាម្ចាស់ ហើយពេលនេះសូមថ្វាយកូនទៅព្រះអង្គវិញ»។ លោកអានបានបន្តថា៖ «ពេលឮថាចូលក្រុមបួស ពួកខ្ញុំឆ្ងល់។ យើងមិនទំនាស់នឹងការត្រាស់ហៅទេ ប៉ុន្តែហេតុអ្វីត្រូវមកកម្ពុជា? ពេលឮថាមកប្រទេសកម្ពុជា យើងបានជំទាស់។ បើនៅកូរ៉េ យើងអាចទៅសួរសុខទុក្ខបាន។ តែបងស្រីម៉ារីណា បានតាំងចិត្តខ្លាំង ពួកខ្ញុំយល់ព្រម និងអធិដ្ឋានសម្រាប់បងស្រី។ ម៉ារីណា ស្រឡាញ់ប្រទេសកម្ពុជាខ្លាំងណាស់ ហើយបានសម្រេចចិត្តបម្រើព្រះជាម្ចាស់នៅស្រុកខ្មែរ មិនមែនកន្លែងផ្សេងនោះទេ។ ពេលនេះខ្ញុំយល់ ជូនពរកូន និងអធិដ្ឋានសម្រាប់កូនស្រីដែរ»។

ចំពោះអត្តចរិករបស់កូនម៉ារីណា អ្នកស្រី លី អូគហ្យុង វីវ៉ានអាណា ជាម្តាយបានរៀបរាប់ថា កូនស្រីគាត់ជាមនុស្សស្មោះត្រង់ និងឧស្សាហ៍ខ្លាំង មិនសូវធ្វើឱ្យឪពុកម្តាយបារម្ភនោះទេ។ គាត់រៀនពូកែ មានការងារល្អ និងចេះជួយអ្នកដទៃថែមទៀតផង។

ចំពោះការជ្រើសរើសអារ៉ាមដូនជីសម្ងាត់នៅប្រទេសកម្ពុជា ដូនជីម៉ារីណា បានរៀបរាប់ថា «ឆ្នាំ២០០៧ ខ្ញុំមកលេងនៅសៀមរាបដើម្បីមើលអង្គរវត្ត ពេលនោះខ្ញុំជួបក្មេងៗច្រើននាក់ ឃើញគាត់សប្បាយមែនទែន ភ្នែកគាត់ថ្លាដូចកែវ ពេលនោះខ្ញុំចាប់ផ្តើមស្រឡាញ់ស្រុកខ្មែរខ្លាំងណាស់»។

បងស្រីម៉ារីណាបានបន្តរៀបរាប់ថា មួយទៀត ដោយសារបន្ទាយព្រាបនៅជិតអារ៉ាមដូនជីកាមែល ដែលបានផ្តល់ឱកាសឱ្យរូបគាត់បានចេញចូលអារ៉ាមនេះញឹកញាប់ និងជួបបងស្រីច្រើននាក់ដើម្បីនិយាយជាមួយគ្នា។ «ពេលនោះ ខ្ញុំទទួលស្គាល់ច្បាស់ថា ការអធិដ្ឋាន ជារបៀបស្រឡាញ់ព្រះជាម្ចាស់ច្រើនជាងសម្រាប់ខ្ញុំ និងឱ្យស្រឡាញ់បងប្អូនគ្រីស្តបរិស័ទផងប្រជាជនទាំងឡាយ។ ដោយសាររបៀបអធិដ្ឋានសំខាន់ និងល្អជាងគេសម្រាប់ខ្ញុំ។ ខ្ញុំចង់រស់នៅក្នុងអារាមកាមែលនេះមែនទែន ខ្ញុំបដិសេធមិនកើត ដោយសារការត្រាស់ហៅរបស់ព្រះជាម្ចាស់ ខ្លាំងណាស់សម្រាប់ខ្ញុំ»។

ក្នុងធម្មទេសនាលោកអភិបាល អូលីវីយេមានប្រសាសន៍ថា ថ្ងៃនេះ តាមរយៈពាក្យសច្ចានីមួយៗ ដូចជា រស់នៅក្នុងភាពក្រីក្រ កាន់ព្រហ្មចារីធម៌ និងស្តាប់បង្គាប់ នៅក្នុងការអធិដ្ឋានទាំងយប់ទាំងថ្ងៃ ដើម្បីបម្រើព្រះសហគមន៍ក្នុងប្រទេសកម្ពុជា និងក្នុងពិភពលោក បងស្រីបានចូលក្នុងការត្រាស់ហៅដ៏វិសុទ្ធពិសេស ដែលណែនាំឱ្យយើងទាំងអស់គ្នាយល់ថា ពិតមែនព្រះជាម្ចាស់បំពេញជីវិតមួយដ៏ពេញលក្ខណៈបាន។

ក្រុមគ្រួសារដូនជីកាមែល (ដូនជីសម្ងាត់) ពីប្រទេសកូរ៉េ បានមកដល់ប្រទេសកម្ពុជាក្នុងឆ្នាំ២០០៥ ស្នាក់នៅក្នុងក្រុងភ្នំពេញ និង ក្រោយមកបានកសាងអារ៉ាមក្នុងស្រុកអង្គស្នួល ខេត្តកណ្តាល។ សព្វថ្ងៃនេះមានយុវនារីជាតិកម្ពុជាមួយរូបកំពុងឈ្វេងយល់ពីជីវិតជាអ្នកបួសក្នុងក្រុមដូនជីកាមែលនេះ៕

ទស្សនាវីដេអូទីនេះ

## យុវនារីខ្មែរ មួយរូបថ្វាយពាក្យសច្ចាលើកដំបូង ក្នុងក្រុមដូនជីនៃសាសនទូតថៃ

*ដោយ៖ លី សុវណ្ណា*

យុវនារីខ្មែរមួយរូបបានថ្វាយពាក្យសច្ចាលើកដំបូងរបស់ខ្លួន ក្នុងក្រុមដូនជីកាតូលិក សាសនទូតថៃនៃក្រុមគ្រួសារ អ្នកបម្រើបេះដូងដ៏និមលរបស់ព្រះនាងម៉ារី នាព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ នៅអារ៉ាមក្រុមដូនជីកាតូលិកសាសនទូត នាខេត្តរាជាបូរី ក្នុងប្រទេសថៃ រួមជាមួយយុវនារីជាតិថៃ៣រូបទៀត។ ដូនជីកាតូលិកថ្មី រូបនេះឈ្មោះ តេរេសា ម៉ៅ ស្រីមិច ដែលមានដើមកំណើតនៅភូមិកំពង់គោ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

ដូនជីវ័យក្មេងរូបនេះ បានរៀបរាប់ឱ្យដឹងថា ខ្លួនមានបងប្អូនប្រុសស្រីចំនួន ៩នាក់ ហើយបងស្រីជាកូនទី៦ នៃគ្រួសារគ្រីស្តបរិស័ទ ដែលឪពុកជាគ្រីស្តបរិស័ទពីកំណើត ហើយម្តាយទើបតែទទួលអគ្គសញ្ញាជ្រមុជទឹក នាពេលដែល ព្រះសហគមន៍មានដំណើរការឡើងវិញ នាទសវត្សរ៍ ១៩៩០។

ដោយការលូតលាស់ ធំដឹងក្តីក្នុងគ្រួសារគ្រីស្តបរិស័ទ ស្រីមិច បានគិតថា ខ្លួនមានសំណាង និងបានរៀនស្គាល់ពីព្រះជាម្ចាស់ មានទំនាក់ទំនងជាមួយគ្រីស្តបរិស័ទ និងទទួលបានសេចក្តីស្រឡាញ់ពីព្រះជាម្ចាស់ទាំងនាងផ្ទាល់ និងក្រុមគ្រួសារ។ ស្រីមិចបញ្ជាក់ថា៖« ការស្តាប់សំឡេង ត្រាស់ហៅរបស់ព្រះជាម្ចាស់តាមរយៈ ជីវិតជាអ្នកថ្វាយខ្លួនជាអ្នកបួស និងការដើរតាមការត្រាស់ហៅរបស់ព្រះជាម្ចាស់សម្រាប់ខ្ញុំ នាំឱ្យខ្ញុំសម្រេចចិត្តជ្រើសរើសក្នុងក្រុមគ្រួសារ អ្នកបម្រើបេះដូងដ៏និមលរបស់ព្រះនាងម៉ារី»។

ដូនជីរូបនេះបន្តថា នាងចាប់អារម្មណ៍យកចិត្តទុកដាក់អំពីជីវិតអ្នកបួស ដោយសារបានឃើញគំរូ និងសកម្មភាពរបស់លោកបូជាចារ្យ ដូនជីអ្នកស្ម័គ្រចិត្តដែលមានបេសកកម្មនៅសាលារៀន នៅព្រះវិហារ និងនៅតាមទីផ្សេងៗទៀត ដោយគ្មានការនឿយហត់បម្រើបងប្អូនអ្នកក្រីក្រ បម្រើយុវជនដែលជាអ្នកទីទាល់ក្រជាដើម ឱ្យគេមានអនាគតល្អភ្លឺស្វាង។ ទាំងអស់នេះជាកត្តាជំរុញឱ្យរូបបងស្រីថ្មីនេះ ចូលក្រុមបួស ដើម្បីបម្រើព្រះសហគមន៍ បងប្អូន និងព្រះជាម្ចាស់ ក្នុងក្រុមដូនជីកាតូលិកគ្រួសារបងស្រី អ្នកបម្រើបេះដូងដ៏និមលរបស់ព្រះនាងម៉ារី។



*តេរេសា ម៉ៅ ស្រីមិច ក្នុងក្រុមដូនជីកាតូលិក សាសនទូតថៃ។ រូបភាព៖ Sr. Jeernan*

ក្រុមគ្រួសារអ្នកបម្រើបេះដូងដ៏និមលរបស់ព្រះនាងម៉ារី បង្កើតឡើងក្នុង ឆ្នាំ ១៩៣៧ ដោយលោកអភិបាលកាយេតាណូ ប៉ាសតទី (SDB) នៅក្នុងប្រទេសថៃ ដើម្បីជួយកិច្ចការងាររបស់លោកបូជាចារ្យ តាមព្រះវិហារ និងជួយអប់រំជំនឿ អប់រំយុវជន យុវនារី និងការងារសង្គ្រោះទាំងឡាយក្នុងព្រះសហគមន៍។ ក្រុមនេះបានមកបំពេញបេសកកម្មនៅកម្ពុជាក្នុងពាក់កណ្តាលទស្សវត្សឆ្នាំ១៩៩០ នៅខេត្តកំពង់ធំ និង សៀមរាប។ បច្ចុប្បន្នក្រុមនេះមានសមាជិក(ថៃនិងខ្មែរ)ទាំងអស់ចំនួន ៩៤ នាក់ ដែលមានដូនជីជាតិកម្ពុជា ចំនួនពីរនាក់៕




ពិធីប្រសិទ្ធពរលើប្រេងក្នុងភាពស្ងៀមស្ងាត់ ដោយមានការចូលរួមពីគ្រីស្តបរិស័ទតែពីរបីនាក់តែប៉ុណ្ណោះ ដើម្បីចូលរួមទប់ស្កាត់នឹងការរីករាលដាលជំងឺវីរ៉ុស កូវីដ១៩។ **រូបភាព៖ ង៉ែត សុធីរិទ្ធិ**

# ពិធីប្រសិទ្ធពរលើប្រេង ក្នុងភាពស្ងៀមស្ងាត់

*ដោយ៖ កែវ កញ្ញា*

នៅក្នុងឆ្នាំនេះ ពិធីបុណ្យប្រសិទ្ធិពរលើប្រេងមានសភាពស្ងៀមស្ងាត់ ដោយសារ តែព្រះសហគមន៍កាតូលិកនៅកម្ពុជាមិនអាចធ្វើពិធីជួបជុំតាមបែបសាសនា ព្រោះតែបម្រាមរបស់រដ្ឋាភិបាលនៅក្នុងអំឡុងពេលកូវីដ១៩។

ជារៀងរាល់ឆ្នាំកម្មវិធីបុណ្យប្រសិទ្ធិពរលើប្រេងបានប្រមូលអស់លោកបូជាចារ្យ ដែលជាគង្វាលនៅតាមព្រះសហគមន៍ទាំងអស់ក្នុងភូមិភាគទាំងបីនៅកម្ពុជា ដោយមានលោកអភិបាលទាំងបីភូមិភាគជាប្រធានកម្មវិធី មានគ្រីស្តបរិស័ទច្រើនកុះករ ជាពេលវេលាមួយដែលបូជាចារ្យរំលឹកពាក្យសច្ចារបស់ខ្លួន និងជាពេលវេលាដែលគ្រីស្តបរិស័ទជូនពរ និងថ្លែងអំណរគុណដល់លោកបូជាចារ្យទាំងអស់ដែលបម្រើក្នុងនាមជាគង្វាលអស់ពីកម្លាំងកាយកម្លាំងចិត្ត។ ប៉ុន្តែនៅឆ្នាំនេះ លោកអភិបាលអូលីវីយេបានធ្វើពិធីនេះរួមជាមួយលោកបូជាចារ្យចំនួន ៣ អង្គប៉ុណ្ណោះ ដោយមានការចូលរួមពីគ្រីស្តបរិស័ទតែពីរបីនាក់។ កម្មវិធីនេះបានធ្វើឡើងកាលពីថ្ងៃទី២ ខែមេសា ឆ្នាំ ២០២០ នៅព្រះវិហារសន្តសិលា និងសន្តប៉ូល នៅរាជធានីភ្នំពេញ។

លោកអភិបាល អូលីវីយេ បានមានប្រសាសន៍ថា៖ «លោកអភិបាលប្រ៊ុយណូ និងអភិបាលគីគេ បានឯកភាពឱ្យខ្ញុំថ្វាយអភិបូជាប្រសិទ្ធពរលើប្រេងថ្ងៃនេះ ដោយលើកការជួបជុំគ្នារបស់បូជាចារ្យទាំងអស់ជាមួយគ្រីស្តបរិស័ទមួយចំនួនដែរ ដើម្បីឱ្យបូជាចារ្យមានឱកាសប្រកាសពាក្យសច្ចាសារជាថ្មីនៅតាំងគោកនៅពេលខាងមុខ តែអត់ដឹងនៅពេលណា»។

ជាទូទៅក្នុងពិធីនេះ លោកបូជាចារ្យទាំងអស់ក៏នឹងថ្វាយពាក្យសច្ចារបស់ខ្លួនឡើងវិញនៅមុខលោកអភិបាលទាំងបី និងព្រះសហគមន៍កាតូលិក គឺរួមមាន កាន់ព្រហ្មចារិធម៌ ស្តាប់បង្គាប់ និងរស់នៅបែបក្រីក្រ។

លោកអភិបាលមានប្រសាសន៍នៅក្នុងធម្មទេសនាថា៖ «ប្រេងទាំងបីនេះ ណែនាំឱ្យយើងចូលសារជាថ្មីនៅក្នុងសារៈសំខាន់នៃជីវិតរបស់យើង។



លោកអភិបាលអូលីវីយេបានធ្វើពិធីបុណ្យប្រសិទ្ធិពរលើប្រេងមានសភាពស្ងៀមស្ងាត់រួមជាមួយលោកបូជាចារ្យចំនួន ៣ អង្គប៉ុណ្ណោះ។ **រូបភាព៖ ង៉ែត សុធីរិទ្ធិ**





សម្រាប់យើងដែលរស់នៅក្នុងពិភពមួយដែលកំពុងភ័យខ្លាច ដែលមានអ្នកស្លាប់យ៉ាងច្រើនទៅៗពីមួយថ្ងៃទៅមួយថ្ងៃ។ ពេលនេះយើងនៅក្បែរប្រេងដែលមានជីវិត»។

ប្រេងដែលលោកអភិបាលបានប្រសិទ្ធពរនោះ មានបីប្រភេទ គឺប្រេងសម្រាប់អ្នកជំងឺ ប្រេងសម្រាប់បងប្អូនទទួលការអប់រំជំនឿ និងយើងមានប្រេងពិសិដ្ឋ ដែលជាប្រេងគ្រីស្មា ដើម្បីធ្វើពិធីអគ្គសញ្ញាដូចជា អគ្គសញ្ញាជ្រមុជទឹក អគ្គសញ្ញាលាបថ្ងាស និងអគ្គសញ្ញាតែងតាំងជាបូជាចារ្យ ឬជាឧបដ្ឋាក ឬជាអភិបាល។

លោកអភិបាលបន្ថែមថា នៅពេលនេះយើងទទួលកម្លាំងកាយ កម្លាំងចិត្តថ្មីពីព្រះយេស៊ូ ដោយដឹងថាព្រះយេស៊ូជាព្រះគ្រីស្ត ដែលទទួលប្រេងអភិសេកពីព្រះបិតា។ លោកអភិបាលបន្ថែមថា៖ «នៅពេលនេះ តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ និងតាមរយៈអគ្គសញ្ញានៃជីវិត តាមរយៈព្រះពរសម្រាប់អ្នកដែលទទួលអប់រំជំនឿទៅជាកម្លាំងយ៉ាងជាក់ស្តែង ទៅជាជីវិតយ៉ាងជាក់ស្តែងរបស់ព្រះជាម្ចាស់ ដែលយាងមកសម្រាប់យើងដែលជាព្រះសហគមន៍»។

> យើងចូលរួមនៅក្នុងសក្ការបូជារបស់ព្រះយេស៊ូផ្ទាល់ខ្លួនដើម្បីឲ្យជីវិតរបស់យើងទៅជាសក្ការបូជារួមជាមួយព្រះគ្រីស្ត និងដើម្បីឲ្យយើងណែនាំជីវិតដ៏បរិបូរណ៍ដល់បងប្អូនរបស់យើងទាំងអស់។

លោកបន្តថា៖ «ប្រេងនេះជាសញ្ញាសម្គាល់យ៉ាងជាក់ស្តែងអំពីសេចក្តីស្រឡាញ់ សេចក្តីក្លាហានរបស់ព្រះជាម្ចាស់ចំពោះយើង»។ សេចក្តីក្លាហាន និងកម្លាំងរបស់ព្រះជាម្ចាស់បានចូលនៅក្នុងប្រេងនេះ ដើម្បីហៀរចូលនៅក្នុងជីវិតរបស់យើង នៅក្នុងខ្លួនយើង ដើម្បីឱ្យយើងជាគ្រីស្តបរិស័ទត្រៀមខ្លួន ដើម្បីទទួលស្វាគមន៍ព្រះយេស៊ូដែលរំដោះយើងពីអំពើបាបពីភាពងងឹត ដើម្បីណែនាំឱ្យយើងទៅរកជីវិត គឺជីវិតដ៏បរិបូរណ៍ ជីវិតអស់កល្បជានិច្ច។

លោអភិបាលបានលើកទឹកចិត្តគ្រីស្តបរិស័ទទាំងអស់ កុំឱ្យអស់សង្ឃឹមក្នុងជំនឿ ហើយកុំគិតថា ព្រះយេស៊ូបោះបង់ប្រជារាស្ត្ររបស់ព្រះអង្គ។ លោកអភិបាល៖ «ព្រះយេស៊ូដឹងច្បាស់យើងនៅក្នុងកាលៈទេសៈយ៉ាងពិបាកនៅក្នុងគ្រាមួយដែលនាំឱ្យពិបាក នៅក្នុងគ្រាអាសន្នប៉ុន្មានប្រទេស នៅក្នុងពេលវេលាសម្ងាត់ ពេលវេលាឯកោនៅក្នុងប៉ុន្មានកន្លែង បីដូចជាខ្យល់ព្យុះយ៉ាងខ្លាំងមែនទែន និងណែនាំឱ្យជីវិតរបស់យើងចង់ដួល ចង់លិច ចង់បាត់អ្វីៗទាំងអស់ ឬបាត់សេចក្តីសង្ឃឹមជាពិសេស ប៉ុន្តែយើងដឹងថា ព្រះយេស៊ូគង់នៅជាមួយយើង និងណែនាំឱ្យខ្យល់ព្យុះនៅស្ងៀមស្ងាត់»។

លោកអភិបាលអូលីវីយេ សូមឱ្យគ្រីស្តបរិស័ទបើកដួងចិត្ត រួមជាមួយទុក្ខលំបាកនៃពិភពលោកទាំងមូល រួមជាមួយមនុស្សជាច្រើនដែលកំពុងស្លាប់ និងកំពុងភ័យខ្លាចដោយសារជំងឺដ៏សាហាវនេះ។ លោកនឹងអធិដ្ឋានសម្រាប់លោកបូជាចារ្យទាំងអស់ ក្នុងអាទិត្យនៃសប្តាហ៍ពិសិដ្ឋ ហើយលោកក៏សូមលើកទឹកចិត្តដល់អស់លោកបូជាចារ្យ ឱ្យណែនាំពិធីបុណ្យត្រៃទិវាមុនបុណ្យចម្លងដោយយកចិត្តទុកដាក់ ទោះបីជាលោកបូជាចារ្យប្រារព្ធពិធីនេះតែម្នាក់ឯង ឬមានគ្រីស្តបរិស័ទ ២-៣នាក់ក្តី។



លោកអភិបាលអូលីវីយេ សូមឱ្យគ្រីស្តបរិស័ទបើកដួងចិត្ត រួមជាមួយទុក្ខលំបាកនៃពិភពលោកទាំងមូល រួមជាមួយមនុស្សជាច្រើនដែលកំពុងស្លាប់ និងកំពុងភ័យខ្លាចដោយសារជំងឺកូវីដ១៩ ដ៏សាហាវ។ **រូបភាព៖ ង៉ែត សុធីរិទ្ធិ**



លោកអភិបាល អូលីវីយេ ដ្មីតអីស្ស៊ែរ ។ **រូបភាព៖ ង៉ែត សុធីរិទ្ធិ**



ប្រេងដែលបានប្រសិទ្ធពរមានបីប្រភេទ គឺប្រេងសម្រាប់អ្នកជំងឺ ប្រេងសម្រាប់បងប្អូនទទួលការអប់រំជំនឿ និងយើងមានប្រេងពិសិដ្ឋ ដែលជាប្រេងគ្រីស្មា ។ **រូបភាព៖ ង៉ែត សុធីរិទ្ធិ**

លោកអភិបាល៖ «ប្រហែលយើងនៅម្នាក់ឯង ជាខ្លួនរបស់យើង ជារូបកាយរបស់យើង ប៉ុន្តែយើងដឹងថា ព្រះជាម្ចាស់ គង់នៅជាមួយយើង និងជាពិសេសប្រជារាស្ត្ររបស់យើង គ្រីស្តបរិស័ទរបស់យើង ជំហានទី២ដែលទន្ទឹងរង់ចាំជីវិតពីយើង ការអធិដ្ឋានពីយើង នៅជាមួយយើងដែរ។ ដូច្នេះ យើងអាចនិយាយថា អាទិត្យពិសិដ្ឋនេះ យើងចូលរួមនៅក្នុងសក្ការបូជារបស់ព្រះយេស៊ូផ្ទាល់ខ្លួនដើម្បីឱ្យជីវិតរបស់យើងទៅជាសក្ការបូជារួមជាមួយព្រះគ្រីស្ត និងដើម្បី ឱ្យយើងណែនាំជីវិតដ៏បរិបូរណ៍ដល់បងប្អូនរបស់យើងទាំងអស់។ រួមគ្នា យើងចូលនៅក្នុងសេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់ដោយអធិដ្ឋាន»។

ដោយសារការជួបជុំបែបសាសនាត្រូវបានហាមឃាត់ ក្នុងឆ្នាំនេះ ព្រះសហគមន៍បានចេញលិខិតនិងឯកសារជាច្រើនដើម្បីជាជំនួយដល់គ្រីស្តបរិស័ទអធិដ្ឋានផ្ទាល់ខ្លួន និងតាមគ្រួសារនីមួយៗ ដោយមានទាំងកម្មវិធីផ្សាយផ្ទាល់តាមរយៈបណ្តាញសង្គមដូចជា ហ្វេសបុក និងយូធូប អំពីអភិបូជា អធិដ្ឋានផ្តាំជារៀងរាល់ថ្ងៃ។ ក្នុងសប្តាហ៍ពិសិដ្ឋនេះ ព្រះសហគមន៍បានចេញនូវឯកបន្ថែមចំនួនទៀត ដើម្បីឱ្យគ្រីស្តបរិស័ទអាចចូលរួមជាមួយគ្នាក្នុងផ្លូវវិញ្ញាណ ជាធ្លុងតែមួយរួមជាមួយព្រះយេស៊ូ៕




ក្នុងអំឡុងពេលការរាត្បាតនៃជំងឺកូវីដ-១៩ យើងមិនអាចជួបជុំគ្នា ដើម្បីថ្វាយអភិបូជា ឬអធិដ្ឋានបានទេ។
ដូច្នេះ ដើម្បីថែរក្សាជំនឿ សូមបងប្អូនអធិដ្ឋានតាមផ្ទះរៀងៗខ្លួន។នៅក្នុងព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញយើង
នឹងមានកម្មវិធីផ្សាយផ្ទាល់ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមដូចជា៖
www.facebook.com/catholicphnompenh ឬ www.facebook.com/RVAKhmer
www.youtube.com/catholicphnompenh ឬ www.youtube.com/RVAKhmer

**+ អភិបូជាថ្ងៃអាទិត្យ ម៉ោង ៩ ព្រឹក | + អភិបូជាថ្ងៃធម្មតា ម៉ោង ៦:៣០ ព្រឹក**
**+ អធិដ្ឋានសូត្រផ្គុំ ប្រចាំថ្ងៃ ម៉ោ ៧ ល្ងាច ដូច្នេះសូមបងប្អូនចូលរួមទាំងអស់គ្នា។**

ទស្សនាវីដេអូទីនេះ

# សូមព្រះជាម្ចាស់នៅជាមួយបងប្អូន!